# បន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោត

# សេចក្តីណែនាំសម្រាប់ការសង្កេតការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ( ខ-៧ )






## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
## អាណត្តិទី៤ ឆ្នាំ២០១៧

# សេចក្តីណែនាំសម្រាប់អ្នកសង្កេតការណ៍រយៈពេលខ្លីពី របៀបសង្កេតការណ៍ និងការបំពេញទម្រង់របាយការណ៍ ក្នុងដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧

**ក. សេចក្តីផ្តើម**

អ្នកសង្កេតការណ៍ នឹងត្រូវធ្វើការសង្កេតនៅថ្ងៃបោះឆ្នោត គឺថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ ចាប់ពីម៉ោង ០៦:០០ នាទី(ព្រឹក) រហូតដល់ការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោតចប់ (លើកលែងករណីប្រធានសក្តិ) ត្រូវយកចិត្តទុកដាក់លើបញ្ហា និងរាល់ភាពមិនប្រក្រតីនានា ព្រមទាំងការរំលោភច្បាប់ បទបញ្ជា និងនីតិវិធី។ អ្នកសង្កេតការណ៍ត្រូវស្ថិតនៅក្នុងទីតាំង ឬមណ្ឌលការិយាល័យបោះឆ្នោតណាមួយ ដែលបានកំណត់ទុកក្នុងករណីទីតាំងនោះ មានការិយាល័យបោះឆ្នោតច្រើនជាងមួយការិយាល័យ នោះអ្នកសង្កេតការណ៍ត្រូវទទួលខុសត្រូវសង្កេតពីរការិយាល័យ។ អ្នកសង្កេតការត្រូវបំពេញទម្រង់សង្កេត និងការបញ្ជូនរបាយការណ៍ និងគោរពក្រមសីលធម៌។

**អក្សរកាត់ដែលប្រើប្រាស់ក្នុងសៀវភៅណែនាំនេះ**

| | |
|---|---|
| គ.ជ.ប (NEC) | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| លធ/ខប (PES) | លេខាធិការដ្ឋានរាជធានី/ខេត្តរៀបចំការបោះឆ្នោត |
| គធ/ខប (PEC) | គណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត |
| គឃ/សប (CEC) | គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត |
| កបឃ/ស (CC) | ក្រុមប្រឹក្សាឃុំ/សង្កាត់ |
| គកប/គករ | គណៈកម្មការការិយាល័យរៀបចំការបោះឆ្នោត និងរាប់សន្លឹកឆ្នោត |
| ច.ប.ត.រ | ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ |
| ច.ប.ឃ.ស | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ |
| ប.ន.ឃ.ស | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសក្រុមប្រឹក្សាឃុំ សង្កាត់ |
| អ.ខ | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ |
| ឯ.អ | ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត |
| ទ. | ទម្រង់បែបបទលេខ |
| ទីតាំងការិយាល័យ | ជាសាលារៀន ឬវត្តអារាម ឬទីកន្លែងសាធារណៈណាមួយ ឬផ្ទះប្រជាពលរដ្ឋណាមួយក្នុងភូមិ |

**ខ.សង្ខេបរបៀបសង្កេត និងពេលវេលា**

**ខ.១ ផ្ញើវត្តមានទៅនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

អ្នកសង្កេតការណ៍ត្រូវទៅឲ្យដល់ការិយាល័យបោះឆ្នោត **(ម៉ោង ៦:០០ ដល់ ៦:៣០ព្រឹក)** ហើយបង្ហាញវត្តមានឱ្យប្រធានការិយាល័យដឹង (បង្ហាញវត្តមានឱ្យបាន ២ការិយាល័យបើទីតាំងនោះមានការិយាល័យច្រើនលើសពីមួយ) និងត្រូវបង្ហាញវត្តមានដល់ភ្នាក់ងារគណបក្សនយោបាយផងដែរ។ ការសង្កេតការណ៍ត្រូវយកចិត្តទុកដាក់ចំពោះសំណួរ **ទី១ ដល់ទី៤ (សង្កេតរាល់ពេលចេញទៅក្រៅ ឬសាកសួរភ្នាក់ងារគណបក្ស ឬអ្នកសង្កេតការណ៍ផ្សេងទៀត)**។

ជាមួយគ្នានេះ អ្នកសង្កេតការណ៍ក៏ត្រូវសាកសួរ(ពេលវេលាសមស្របណាមួយ)ជាមួយភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ផ្សេងទៀតថា តើមានស្ថានភាពគួរកត់សម្គាល់ដែរឬទេ?។

<u>ក្រៅពីម៉ោងដែលបានកំណត់ខាងលើ សំណួរទី២ ដល់ទី៤ ក៏នៅតែធ្វើការសង្កេតដដែល ព្រោះវាជាសំណួរទូទៅក្នុងការសង្កេត។</u>

**ខ.១.១ សង្ខេបនីតិវិធីសម្រាប់សំណួរទី១ ដល់ទី៤**

**សម្រាប់សំណួរទី១ ដល់ ទី៤ (ច.ប.ឃ.ស មាត្រា ១០)** អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលទទួលខុសត្រូវការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការងារដទៃទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត និងក្រោយសម័យបោះឆ្នោត។

**សម្រាប់សំណួរទី១ (ប.ន.យ.ស ជំពូក៩ ប្រការ៩.៦ និងចំណុច ៩.៦.២)**

គ.ក.ប ត្រូវចូលដល់ទីតាំងការិយាល័យ ដោយនាំមកនូវជាមួយសម្ភារៈ ឯកសារបោះឆ្នោត ឱ្យបានទាន់ម៉ោង៦ព្រឹកនាថ្ងៃបោះឆ្នោតជាកំហិត ដើម្បីគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត។ ប្រធាន គ.ក.ប ចាត់ចែងសមាជិកទី២ និងសមាជិកដទៃទៀតឱ្យរៀបចំដាក់សម្ភារៈឯកសារសម្រាប់ការបោះឆ្នោត។




**សម្រាប់សំណួរទី២ (ប.ន.យ.ស ជំពូក៩ ចំណុច ៩.៦.១)**

បន្ទាប់ពី គកប បានចូលដល់ការិយាល័យបោះឆ្នោតភ្លាម ប្រធានត្រូវប្រកាសឲ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ចូលក្នុងការិយាល័យបោះឆ្នោត ដោយធ្វើការត្រួតពិនិត្យស្លាកសម្គាល់ ឬ/និងសេចក្តីសម្រេចតែងតាំង និងទទួលស្គាល់ជាផ្លូវការម្នាក់ម្តងៗ និងប្រាប់ទីកន្លែងដែលបម្រុងទុកសម្រាប់ពួកគេ។

**ឧទាហរណ៍សម្រាប់សំណួរទី៣** ជនណាម្នាក់បានយកលុយ ឬសម្ភារៈទៅឲ្យអ្នកបោះឆ្នោតជាសំណូក ឬទិញសន្លឹកឆ្នោត ដើម្បីបង្អាក់អ្នកបោះឆ្នោត (តិច ឬច្រើន) មិនឲ្យបោះឆ្នោត ឬទៅបោះឆ្នោត វាជាទង្វើបង្កឲ្យបាត់បង់សិទ្ធិរបស់ប្រជាពលរដ្ឋចូលរួមក្នុងការបោះឆ្នោតដោយសេរី និងយុត្តិធម៌។

**សម្រាប់សំណួរទី៤ (ច.ប.យ.ស មាត្រា២៨ និង ប.ន.យ.ស ជំពូក៥ ប្រការ ៥.៦.១ ចំណុច៥.៦.១.២/៣)**

ភ្នាក់ងារសន្តិសុខមានបំពាក់អាវុធដែលត្រូវបានតែងតាំងអាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធ។ ហាមនាយ ឬពលនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិណាម្នាក់ចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬឈរជិតបរិវេណការពារសន្តិសុខឡើយ ប្រសិនអ្នកទាំងនោះមិនទៅបោះឆ្នោតទេនោះ លើកលែងតែអ្នកទាំងនោះត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខ។

| ល.រ | សំណួរ ៦ ( គម្រាមកំហែងរារាំង និងអសន្តិសុខ) | មាន បញ្ហា | ចំនួន ករណី | សរុប បណ្តឹង (គាំផ្ទាល់មាត់ ឬ លាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ១ | តើមានបញ្ហាខ្វះសម្ភារៈមួយចំនួនបង្កឲ្យមានការរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត និង/ឬរាប់សន្លឹកឆ្នោត ដែរឬទេ? | ☐ | | | |
| ២ | តើមានការបដិសេធមិនឲ្យអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយចូលសង្កេតក្នុងការិយាល័យបោះឆ្នោត និង/ឬរាប់សន្លឹកឆ្នោតដែរឬទេ? | ☐ | | | |
| ៣ | តើមានការរារាំងអ្នកបោះឆ្នោតដោយវិធីផ្តល់លុយកាក់ ឬសម្ភារៈ ដើម្បីកុំឲ្យទៅបោះឆ្នោតដែរឬទេ? | ☐ | | | |
| ៤ | តើមាន**មន្ត្រីជាអាជ្ញាធរមូលដ្ឋាន ឬកងកំលាំងប្រដាប់អាវុធ** (ដែលមិនមានពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប) ស្លៀកពាក់ឯកសណ្ឋាន និង/ឬមានសកម្មភាពយកអាវុធជាតិផ្ទុះ ឬប្រើពាក្យសម្តីគំរាមកំហែង បំភិតបំភ័យនៅខាងក្នុង ឬនៅបរិវេណខាងក្រៅឬក្បែរការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ដែរឬទេ? | ☐ | | | |

**បើមានករណីកើតឡើង** សូមបញ្ជាក់ពីការិយាល័យ? ពេលវេលា? ជនរងគ្រោះ ជនប្រព្រឹត្ត ឬគណបក្សណា មានសកម្មភាពយ៉ាងដូចម្តេច?..........................................................................................................................................................................។

## ខ.២ មុនដំណើរ និងដំណើរការបោះឆ្នោត ( ម៉ោង ៦:៣០ ដល់ ៧:០០ព្រឹក )

អ្នកសង្កេតការណ៍ត្រូវជ្រើសរើសការិយាល័យបោះឆ្នោតមួយ ហើយស្ថិតនៅខាងក្នុងដើម្បីធ្វើការសង្កេតដោយផ្តោតសំខាន់លើសំណួរ **ទី៥ ទី៦ និងទី៧**។

### ខ.២.១ សង្ខេបនីតិវិធីសម្រាប់សំណួរទី៥ ដល់ទី៧

**សម្រាប់សំណួរទី៥ (ប.ន.យ.ស ជំពូកទី៩ ចំណុច ៩.៦.៤.២)**

ប្រធានត្រូវបើកគម្របក្រៅ និងគម្របក្នុងនៃហិបឆ្នោត **រួចបង្ហាញហិបឆ្នោតទទេ** ចំពោះអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកត្រូវបិទគម្របក្នុងនៃហិបឆ្នោតទៅវិញ មួលភ្ជិតគម្របសន្ទះបិទប្រឡោះសម្រាប់បោះឆ្នោត ហើយខ្ទាស់គន្លឹះគម្របក្នុង រួចចាក់សោឃ្លុំ និងបង្គាប់ឲ្យលេខាធិការកត់ត្រាលេខសោឃ្លុំនោះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត។




**សម្រាប់សំណួរទី៦ (ប.ន.ឃ.ស ជំពូកទី៩ ចំណុច ៩.៦.៨)**

ប្រធាន គ.ក.ប **ត្រូវប្រកាសបើកការិយាល័យបោះឆ្នោតរបស់ខ្លួននៅម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកនៃថ្ងៃបោះឆ្នោត** និងអញ្ជើញសមាសភាព គ.ក.ប ឱ្យបោះឆ្នោតមុនគេបង្អស់ រួចបន្ទាប់មកភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ប្រសិនបើអ្នកទាំងនេះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។... ប្រសិនបើប្រធាន គ.ក.ប មិនអាចប្រកាសបើកការិយាល័យបោះឆ្នោតនៅក្រោយម៉ោង ៧:០០(ប្រាំពីរ) ព្រឹកបាន គាត់អាចប្រកាសបើកការិយាល័យបោះឆ្នោតនៅក្រោយម៉ោង ៧:០០ (ប្រាំពីរ)ព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោង ៨:០០(ប្រាំបី) ព្រឹកឡើយ។

**សម្រាប់សំណួរទី៧ (ប.ន.ឃ.ស ជំពូកទី៩ ចំណុច៩.៦.២.៣)**

**បន្ទប់សម្ងាត់សម្រាប់បិទបាំងការគូសសន្លឹកឆ្នោតចំនួន ០២(ពីរ)** ដែលមានបិចចងខ្សែភ្ជាប់ស្រាប់ តដាក់នៅលើតុពីរ (២) ក្បែរជញ្ជាំងប្រមាណមួយម៉ែត្រកន្លះ ពីជញ្ជាំង និងមានចម្ងាយពីគ្នាយ៉ាងតិច១(មួយ)ម៉ែត្រ **ប៉ុន្តែមិនត្រូវដាក់នៅក្បែរបង្អួចទេ។** ផ្ទាំងក្រដាសសម្រាប់ទ្រាប់គូសសន្លឹកឆ្នោត០១(មួយ)សន្លឹក ត្រូវបិទភ្ជាប់ទៅនៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់នីមួយៗ ត្រូវមានពន្លឺគ្រប់គ្រាន់។

| ល.រ | សំណួរ ៦ ( ភាពមិនប្រក្រតី នៃនីតិវិធី ) | មាន បញ្ហា | ចំនួន ករណី | សរុប បណ្ដឹង (តវ៉ាផ្ទាល់មាត់ ឬ លាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ៥ | តើមានការ**មិនបង្ហាញហិបឆ្នោតទទេ** មុនពេលចាប់ផ្ដើមដំណើរការបោះឆ្នោតដែរឬទេ? | ☐ | | | |
| ៦ | តើមានការបើកការិយាល័យបោះឆ្នោត**យឺត**ជាងម៉ោង ៧:០០នាទីព្រឹក ដោយគ្មានមូលហេតុត្រឹមត្រូវដែរឬទេ? (បើកមិនតាមពេលកំណត់) | ☐ | | | |
| ៧ | តើមានភាពមិនប្រក្រតីនានាដែលនាំឱ្យ**បាត់ភាពសម្ងាត់**នៃការបោះឆ្នោតដែរឬទេ? (ដូចជាជញ្ជាំងរហែក ការសាកសួរ ការលបមើល ការបើកបង្អួចមើលការថតរូប ឬការិយាល័យបោះឆ្នោតនៅក្រោយផ្ទះប្រជាពលរដ្ឋ ដែលអាចមើលឃើញ) | ☐ | | | |

## ខ.៣ របៀបសង្កេតដំណើរការបោះ និងពេលវេលា ( ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៣:០០រសៀល )

ចាប់ពីម៉ោង ៧:០០នាទីព្រឹករហូតដល់ម៉ោង ៣:០០ រសៀល ការិយាល័យបោះឆ្នោតបានបើកដំណើរការ (មាននៅក្នុងជំពូកទី១០ នៃ ប.ន.ឃ.ស) នៅពេលនោះ**ប្រធាន គ.ក.ប** ប្រកាសឱ្យដំណើរការបោះឆ្នោត ដោយឱ្យសមាជិក គ.ក.ប ទាំងអស់បោះឆ្នោតមុនគេ បន្ទាប់មកភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន រួចប្រជាពលរដ្ឋដែលមានបំណងមកបោះឆ្នោត។ ជនពិការ ចាស់ជរា ព្រះសង្ឃ ស្ត្រីមានក្មេងតូច ស្ត្រីមានផ្ទៃពោះ ផ្ដល់អាទិភាពមុនគេ។




ជាដំបូង **សមាជិកទី២** ត្រូវរៀបចំសណ្ដាប់ធ្នាប់ឱ្យអ្នកបោះឆ្នោតឈរតម្រង់ជួរ និងជួយស្វែងរកឈ្មោះឱ្យអ្នកបោះឆ្នោត។ **សមាជិកទី៣**ដែលឈរនៅមាត់ទ្វាការិយាល័យត្រូវផ្ដល់សិទ្ធិអាទិភាពអ្នកបោះឆ្នោតចូលក្នុងការិយាល័យបោះឆ្នោត រំឭកអ្នកបោះឆ្នោតឱ្យរកមើលឈ្មោះរបស់គាត់ និងឱ្យ

អ្នកបោះឆ្នោតចូលម្តងម្នាក់ៗ តម្រង់ទៅតុលេខាធិការ។ អ្នកបោះឆ្នោតត្រូវសំដៅទៅលេខាធិការ គ.ក.ប ពេលនោះ**លេខាធិការ គ.ក.ប** ត្រួតពិនិត្យស្នាមម្រាមដៃ ពិនិត្យលេខរៀងនៅលើបណ្ណព័ត៌មានអ្នកបោះឆ្នោត(បើមាន) សួរបញ្ជាក់ឈ្មោះ ពិនិត្យផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ ជាមួយរូបថត និងទិន្នន័យផ្សេងទៀត។ ដាក់បន្ទាត់តម្រង់តាមបណ្តោយជួរឈ្មោះរបស់គាត់ ហុច អ.ខ/ឯ.អ បន្តទៅអនុប្រធាន និងជម្រាបគាត់ឱ្យទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន។ **អនុប្រធាន គ.ក.ប** ហែកសន្លឹកឆ្នោត ១សន្លឹកចេញពីគល់បញ្ជីសន្លឹកឆ្នោត បោះត្រាសម្ងាត់ខាងខ្នងលើសន្លឹកឆ្នោត និងបត់ជា ៤ផ្នត់។ អនុប្រធាន គ.ក.ប ណែនាំពីរបៀបគូស របៀបបត់សន្លឹកឆ្នោតតាមផ្នត់ដើមក្រោយពីគូសរួច និងណែនាំឱ្យទៅកាន់បន្ទប់គូស និងណែនាំដើរទៅកាន់តុដាក់ហិបឆ្នោតព្រមទាំងបង្ហាញពីត្រាសម្ងាត់នៅខាងខ្នងបង្ហាញសមាជិកទី១ មុនដាក់ចូលហិបឆ្នោត។ សមាជិកទី១ គ.ក.ប ដែលឈរនៅក្បែរហិបឆ្នោត ឱ្យអ្នកបោះឆ្នោតបង្ហាញត្រាសម្ងាត់នៅលើខាងខ្នងសន្លឹកឆ្នោត និងឱ្យស៊កចូលក្នុងហិបឆ្នោត ព្រមទាំងជូត និងជ្រលក់ឱ្យលិចដល់គល់ក្រចកនៃម្រាមចង្អុលដៃស្តាំ ឬម្រាមផ្សេងទៀតចូលទៅក្នុងដបទឹកខ្មៅ និងរង់ចាំ ៣០វិនាទី ព្រមទាំងឱ្យគាត់ចាកចេញពីការិយាល័យ។

## គន្លឹះសំខាន់ៗនៃដំណើរការបោះឆ្នោត សម្រាប់អ្នកសង្កេតការណ៍ត្រូវយកចិត្តទុកដាក់

- សំភារៈសម្រាប់ប្រើប្រាស់ក្នុងការិយាល័យបោះ/រាប់សន្លឹកឆ្នោត
- ការអនុញ្ញាតចូលរួមសង្កេតការណ៍របស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍
- សកម្មភាពសន្តិសុខ សុវត្ថិភាព ការគំរាមកំហែងផ្សេងៗដល់អ្នកបោះឆ្នោត
- ការបង្ហាញហិបឆ្នោត ការត្រួតពិនិត្យលើភាពស្របច្បាប់ និងមិនស្របច្បាប់សម្រាប់អ្នកបោះឆ្នោត
- ភាពសម្ងាត់នៃការបោះឆ្នោតសម្រាប់អ្នកបោះឆ្នោត
- **ជាពិសេសអ្នកសង្កេតការណ៍ត្រូវភ្នែកវាងវៃ ស្តាប់ និងសាកសួរភ្នាក់ងារគណបក្សពីភាពមិនប្រក្រតីដែលអ្នកមិនដឹង**

**ខ.៣.១ ចាប់ពីម៉ោង ៧:០០ ដល់ ៩:០០ព្រឹក**

អ្នកសង្កេតការណ៍ ត្រូវស្ថិតនៅខាងក្នុង ដើម្បីសង្កេតនៅដំណើរការបោះឆ្នោតដោយផ្តោតលើសំណួរ**ទី៨ ដល់ទី១៣** ។

**ខ.៣.១.១ សង្ខេបនីតិវិធីសម្រាប់សំណួរទី៨ ដល់១៣**

**សម្រាប់សំណួរទី៨ (ប.ន.ឃ.ស ជំពូកទី៩ ចំណុច៩.៦.១០.២ ចំណុច៩.៦.១១.១ ចំណុច៩.៦.១១.២ និងចំណុច ៩.៦.១៤)**

**ត្រួតពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត** ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបមិនជ្រះជាប់នៅលើម្រាមដៃគាត់ទេ។ ...**ពិនិត្យផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ** របស់គាត់ជាមួយរូបពិត រួច**ពិនិត្យផ្ទៀងផ្ទាត់ជាមួយរូបថត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត**។ ... អនុប្រធានត្រូវហែកសន្លឹកឆ្នោត០១(មួយ)សន្លឹកចេញពីគល់បញ្ជីរួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង និងបត់ជា ០៤(បួន)ផ្នត់ តាមការកំណត់របស់ គ.ជ.ប ហើយប្រគល់ជូនអ្នកបោះឆ្នោត រួមជាមួយ អ.ខ ឬឯ.អ របស់គាត់។

**សម្រាប់សំណួរទី៩ (ប.ន.ឃ.ស ជំពូកទី៩ ចំណុច៩.៦.២៩)**

ក្នុង**កាលៈទេសៈមានអាសន្ន ដែលនាំឲ្យមានគ្រោះថ្នាក់ ឬការគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងបរិវេណការិយាល័យបោះឆ្នោត** ប្រធាន គ.ក.ប អាចសម្រេចមិនបើក ឬអាចបិទការិយាល័យបោះឆ្នោតរបស់ខ្លួន ដោយផ្អែកតាមការកំណត់របស់ គ.ជ.ប ...។

**សម្រាប់សំណួរទី១០ (ប.ន.ឃ.ស ជំពូកទី៩ ចំណុច ៩.៦.១១.២ និង ៩.៦.១១.៣)**

**ពិនិត្យមើលលេខរៀងនៅលើបណ្ណព័ត៌មាន(ប្រសិនបើមាន)ដើម្បីរកឈ្មោះអ្នកបោះឆ្នោត** រួចប្រគល់បណ្ណព័ត៌មានជូនអ្នកបោះឆ្នោតវិញ។ បន្ទាប់មកសួរបញ្ជាក់ឈ្មោះ ពិនិត្យផ្ទៀងផ្ទាត់ អ.ខ ឬឯ.អ ជាមួយនឹងរូបពិត **រួចពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត**។ ដាក់បន្ទាត់តម្រង់តាមបណ្តោយជួរឈ្មោះរបស់គាត់ និងគូសសញ្ញាធិច បញ្ជាក់ការបានមកបោះឆ្នោតរបស់អ្នកបោះឆ្នោតក្នុងកូនប្រអប់ទំនេរ...។

លេខាធិការពិនិត្យរកមើលស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត



**សម្រាប់សំណួរទី១១ (ប.ន.ឃ.ស ជំពូកទី៩ ចំណុច ៩.៦.១១.១ ចំណុច៩.៦.១២ និងចំណុច៩.៦.១៣.១)**

លេខាធិការត្រួត**ពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថាគ្មានស្នាមទឹកខ្មៅលុបមិនជ្រះជាប់នៅលើម្រាមដៃគាត់ទេ។ នៅពេលលេខាធិការរកមិនឃើញថា មានឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតទេ** ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គកប ដើម្បីរាយការណ៍ពីករណីនេះ។ ប្រធានត្រូវប្រាប់អ្នកបោះឆ្នោតនោះថា គាត់មិនអាចបោះឆ្នោតនៅការិយាល័យនេះបានទេ ព្រោះទោះបីគាត់មាន អ.ខ ឬ ឯ.អ ក្តីប៉ុន្តែគាត់គ្មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះទេ។

**សម្រាប់សំណួរទី១២ (ប.ន.ឃ.ស ជំពូកទី៩ ចំណុច ៩.៦.៣.៣ ចំណុច៩.៦.១៦.៥)**

**អ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយ ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត។** ...លាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវមានទោសដោយផ្អែកតាម ច.ប.ឃ.ស។

**សម្រាប់សំណួរទី១៣ (ប.ន.ឃ.ស ជំពូកទី៩ ចំណុច ៩.៦.២៣.៨)**

ប្រធានត្រូវផ្តល់**ពាក្យបណ្តឹង (ទ.១២០២) សម្រាប់បំពេញពាក្យបណ្តឹង ប្រសិនបើភ្នាក់ងារគណបក្សនយោបាយ ស្នើសុំសម្រាប់ប្តឹងបន្តទៅ គឃ.សប ។**

**ឧទាហរណ៍សម្រាប់ភាពមិនប្រក្រតីផ្សេងទៀត៖** បើមានបញ្ហាមិនប្រក្រតីណាមួយ ឬច្រើន កើតមានឡើង ហើយពុំមានក្នុងសំណួរដែលខុមហ្វ្រែលស្នាក់ការកណ្តាលបានរៀបរាប់ខាងលើ សូមអ្នកសង្កេតការណ៍ធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ពីបញ្ហានោះនៅក្នុងសំណួរ "**ភាពមិនប្រក្រតីផ្សេងៗ**"។

| ល.រ | សំណួរ ៦ ( ភាពមិនប្រក្រតី នៃនីតិវិធី ) | មាន បញ្ហា | ចំនួន ករណី | សរុប បណ្តឹង (តវ៉ាផ្ទាល់មាត់ ឬលាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ៨ | **តើមានករណីណាមួយ ឬច្រើនខាងក្រោមបានកើតឡើងដែរឬទេ?** | | | | |
| | ៨.១ ការមិនពិនិត្យម្រាមដៃ និង/ឬមិនជ្រលក់ទឹកខ្មៅលុបលាងមិនជ្រះ | ☐ | | | |
| | ៨.២ ការមិនពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្នុងឯកសារ និងបញ្ជីបោះឆ្នោត | ☐ | | | |
| | ៨.៣ ការឲ្យសន្លឹកឆ្នោតលើសពីមួយសន្លឹក | ☐ | | | |
| ៩ | តើមានការផ្អាក ឬបិទការិយាល័យនៅពេលកំពុងដំណើរការបោះឆ្នោតជាយថាហេតុ (ហេតុដែលមិនបានដឹងជាមុនដូចជា ខ្យល់ព្យុះ រញ្ជួយផែនដី ទឹកជំនន់ អគ្គីភ័យ អសន្តិសុខ ឬបាក់អាគារ...) ដែរឬទេ? | ☐ | | | |

**បើមានករណីកើតឡើង** សូមបញ្ជាក់ពីការិយាល័យ? ពេលវេលា? ជនរងគ្រោះ ជនប្រព្រឹត្ត ឬគណបក្សណា មានសកម្មភាពយ៉ាងដូចម្តេច?.....
.......................................................................................................................................................................
.......................................................................................................................................................................។

| ល.រ | សំណួរ ៦ ( សិទ្ធិអ្នកបោះឆ្នោត) | មាន បញ្ហា | ចំនួន ករណី | សរុប បណ្តឹង (តវ៉ាផ្ទាល់មាត់ ឬលាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ១០ | **តើមានករណីអ្នកមានសិទ្ធិបោះឆ្នោតមិនបានបោះឆ្នោត ដោយសារមូលហេតុដូចខាងក្រោមដែរឬទេ? (ក្នុងការិយាល័យបោះឆ្នោត)** | | | | |
| | ១០.១ គ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (មានឯកសារនិងឈ្មោះក្នុងបញ្ជីបោះឆ្នោត) | ☐ | | | |
| | ១០.២ មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ | ☐ | | | |
| | ១០.៣ ខុសទិន្នន័យ (ឈ្មោះ ឬភេទ ឬថ្ងៃខែឆ្នាំកំណើត...) | ☐ | | | |
| | ១០.៤ ឈ្មោះរបស់ខ្លួនត្រូវបានបញ្ជាក់ថា បោះរួចហើយ | ☐ | | | |
| | ១០.៥ រកឈ្មោះមិនឃើញ(បាត់ឈ្មោះ)ឬរកការិយាល័យបោះឆ្នោតមិនឃើញ | ☐ | | | |
| | ១០.៦ ផ្សេងៗ........................................................ | ☐ | | | |
| ១១ | **តើមានករណីដូចខាងក្រោមត្រូវបានអនុញ្ញាតឲ្យបោះឆ្នោតម្តងទៀតដែរឬទេ?** | | | | |

| | | | | | |
|---|---|---|---|---|---|
| | ១១.១ អ្នកគ្មានសិទ្ធិបោះឆ្នោត និង/ឬគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត | ☐ | | | |
| | ១១.២ អ្នកមានស្នាមទឹកខ្មៅនៅម្រាមដៃសំគាល់ថា បានបោះឆ្នោតរួចហើយ | ☐ | | | |
| ១២ | តើមានអ្នកបោះឆ្នោតបានយកសន្លឹកឆ្នោតចេញមកខាងក្រៅការិយាល័យបោះឆ្នោត ដើម្បីគូសឲ្យអ្នកបោះឆ្នោតផ្សេងទៀត ហើយយកទៅដាក់ក្នុងហិបឆ្នោតជាបន្តបន្ទាប់គ្នាដែរឬទេ? | ☐ | | | |

**បើមានករណីកើតឡើង** សូមបញ្ជាក់ពីការិយាល័យ? ពេលវេលា? ជនរងគ្រោះ ជនប្រព្រឹត្ត ឬគណបក្សណា មានសកម្មភាពយ៉ាងដូចម្តេច?.....

.......................................................................................................................................................

......................................................................................................................................................។

| ល.រ | សំណួរ ៦ ( ការប្តឹងតវ៉ារបស់តំណាងគណបក្សនយោបាយ) | មានបញ្ហា | ចំនួនករណី | សរុប បណ្តឹង (តវ៉ាផ្ទាល់មាត់ ឬលាយលក្ខអក្សរ) | សរុបការជំទាស់និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ១៣ | តើមានការ**បដិសេធ** ឬ**មិនអើពើ** ឬ**មិនព្រមប្រគល់ទម្រង់ប្តឹងតវ៉ាឬជំទាស់(លេខ១២០២)**ទៅអ្នកបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ ពីសំណាក់មន្ត្រីការិយាល័យបោះឆ្នោតដែរឬទេ? | ☐ | | | |

**បើមានករណីកើតឡើង** សូមបញ្ជាក់ពីការិយាល័យ? ពេលវេលា? ជនរងគ្រោះ ជនប្រព្រឹត្ត ឬគណបក្សណា មានសកម្មភាពយ៉ាងដូចម្តេច?.....

.......................................................................................................................................................

......................................................................................................................................................។

**ខ.៣.២ ចាប់ពីម៉ោង ៩:០០ ដល់ ១០:០០ព្រឹក**

អ្នកសង្កេតការណ៍ត្រូវចេញទៅមើលការិយាល័យមួយទៀតនៅក្បែរគ្នា តែខណៈនៅខាងក្រៅមិនទាន់ចូលក្នុងការិយាល័យមួយទៀត សូមផ្តោតលើសំណួរ**ទី១២ និងទី១៤** ។

ក្រៅពីការសង្កេតអំពីភាពមិនប្រក្រតីក្នុងទម្រង់សំណួរ អ្នកសង្កេតការណ៍អាចជួយណែនាំអ្នកបោះឆ្នោត និងជូនដំណឹងទៅមន្ត្រីការិយាល័យ (សមាជិកទី២ ឬប្រធានការិយាល័យ) នៅពេលមានប្រជាពលរដ្ឋជួបបញ្ហាក្នុងការរកឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតមិនឃើញ(តែកុំបង្កើតការរំខាន)។ ជាមួយគ្នានេះ អ្នកសង្កេតការណ៍ត្រូវថតរូបអំពីទិដ្ឋភាពទូទៅនៅបរិវេណខាងក្រៅការិយាល័យបោះឆ្នោត ដូចជាសកម្មភាពរកឈ្មោះរបស់ប្រជាពលរដ្ឋ ការតម្រង់ជួរ និងសកម្មភាពផ្សេងទៀត (ប្រសិនបើមានឧបករណ៍សម្រាប់ថត)។

## ខ.៤ របៀបសង្កេតដំណើរការបោះឆ្នោតមិនការបោះឆ្នោត ( ម៉ោង ១០:០០ព្រឹក ដល់ ៣:០០នាទីល្ងាច )

អ្នកសង្កេតការណ៍ត្រូវចូលសង្កេតការណ៍នៅក្នុងការិយាល័យបោះឆ្នោតនៃទីតាំងការិយាល័យបោះឆ្នោតនោះ។ ការសង្កេតត្រូវយកចិត្តទុកដាក់ទៅលើភាពមិនប្រក្រតីដូចក្នុង**ចំណុច ខ.៣** និង**ភាពមិនប្រក្រតីផ្សេងទៀត**។

ចាប់ពីម៉ោង១០:០០នាទីព្រឹក ដល់ម៉ោង ៣:០០នាទីរសៀល ក្នុងអំឡុងពេលនេះ អ្នកសង្កេតការណ៍ក៏អាចចេញមកសង្កេតនៅបរិវេណខាងក្នុង ឬក្រៅនៃទីតាំងការិយាល័យបោះឆ្នោតនោះតាមស្ថានភាពជាក់ស្តែង។

**ខ.៤.១ សម្រាប់ម៉ោង ៣:០០រសៀល (ការបិទការបោះឆ្នោត)**

នៅវេលាម៉ោងប្រមាណ៣:០០(បី)រសៀល ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ (ថ្ងៃខែឆ្នាំដែលនៃថ្ងៃបោះឆ្នោត) ការិយាល័យបោះឆ្នោតក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត ហើយគណៈកម្មការបោះឆ្នោត "គ.ក.ប" ក្លាយជាគណៈកម្មការរាប់សន្លឹកឆ្នោត "គ.ក.រ" ។

អ្នកសង្កេតការណ៍ត្រូវជ្រើសរើស និងចូលទៅសង្កេតខាងក្នុងការិយាល័យណាមួយហើយចាប់ផ្តើមសង្កេតដំណើរការបញ្ចប់ការបោះឆ្នោត ការរៀបចំកំណត់ហេតុ និងដំណើរការរាប់សន្លឹកឆ្នោត។

អ្នកសង្កេតការណ៍ត្រូវផ្តោត**លើសំណួរទី១៥** ដែលជាតារាងធ្វើការផ្ទៀងផ្ទាត់ពីចំនួនសន្លឹកឆ្នោតដែលបានបោះឆ្នោត ជាមួយចំនួនអ្នកបោះឆ្នោត ក្រោយបិទការិយាល័យបោះឆ្នោត។

អ្នកសង្កេតការណ៍ក៏ត្រូវសាកសួរភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍ផ្សេងទៀតអំពីភាពមិនប្រក្រតីនានា ឬបណ្តឹងដែលកើតមាន (តវ៉ាផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ)។ ជាមួយគ្នានេះត្រូវសាកសួរប្រធានការិយាល័យបោះឆ្នោតថា តើមានការតវ៉ា ឬបណ្តឹងដែរឬទេ? និងព្រមទាំងសាកសួរមន្ត្រីការិយាល័យបោះឆ្នោតអំពីចំនួនអ្នកមកបោះឆ្នោត។

**១៥. សន្លឹកឆ្នោតក្រោយពេលបញ្ចប់ការបោះឆ្នោតក្នុងការិយាល័យនោះ(ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត និងចំនួនសន្លឹកឆ្នោត)**

| ប្រភេទសន្លឹកឆ្នោត | ចំនួនសន្លឹកឆ្នោត (ជាលេខ និងជាអក្សរ) | |
|---|---|---|
| ក) ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង | ចំនួនៈ ...............សន្លឹក | ចំនួនៈ ..............................................សន្លឹក |
| ខ) ចំនួនសន្លឹកឆ្នោតខូច | ចំនួនៈ ...............សន្លឹក | ចំនួនៈ ..............................................សន្លឹក |
| គ) ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ | ចំនួនៈ ...............សន្លឹក | ចំនួនៈ ..............................................សន្លឹក |
| ឃ) ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត {ឃ = ក - (ខ + គ)} | ចំនួនៈ ...............សន្លឹក | ចំនួនៈ ..............................................សន្លឹក |

**ខ.៥ របៀបសង្កេតដំណើរការរាប់សន្លឹកឆ្នោត** ( **ម៉ោង ៣រសៀល រហូតដល់បញ្ចប់ការរាប់សន្លឹកឆ្នោត** )



ក្រោយពីបិទការិយាល័យបោះឆ្នោត និងធ្វើការផ្ទៀងផ្ទាត់ចំនួនអ្នកបានបោះឆ្នោតជាមួយ សន្លឹកឆ្នោតដែលបានប្រើប្រាស់ ដូចសំណួរទី១៥ រួចមក **ប្រធាន គ.ក.រ** ប្រកាសចាប់ផ្តើមដំណើរការរាប់សន្លឹកឆ្នោត។ ដំណាក់កាលដំបូង ប្រធាន គ.ក.រ កាត់ផ្តាច់សោរឃ្លុំ បើកគម្របខាងក្នុងហិបឆ្នោត ចាក់សន្លឹកឆ្នោតចេញពីក្នុងហិប រួចឱ្យ **សមាជិកទី១** រើសយកវត្ថុដែលមិនមែនជាសន្លឹកឆ្នោត(បើមាន)រួចឱ្យ **លេខាធិការ** កត់ត្រាវត្ថុដែលមិនមែនជាសន្លឹកឆ្នោតចូលក្នុងរបាយការណ៍ ទ.១១០២ បន្ទាប់មកឱ្យ**អនុប្រធាន** លា និងតម្រៀបសន្លឹកឆ្នោតដែលត្រូវបានចាក់ចេញពីហិបឆ្នោតដោយដាក់ផ្កាប់ចុះក្រោម មួយបាច់ចំនួន ២៥សន្លឹក នៅក្នុងពំនូកទី១។

ប្រធាន គ.ក.រ ប្រកាសឱ្យឮៗ អំពីគណបក្សនយោបាយដែលសន្លឹកឆ្នោតនោះត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ។ ចាត់អនុប្រធាន និងលេខាធិការ ឱ្យគូសពិន្ទុ១ សម្រាប់សន្លឹកឆ្នោត ១សន្លឹក ដែលគណបក្សនយបាយពាក់ព័ន្ធបានទទួលនៅក្នុងតារាងកត់ត្រាសំឡេងឆ្នោត(ទ.១១០៨)។ ចាត់សមាជិកទី១ គូសពិន្ទុ១ ដោយប្រើហ្វឺតនៅលើផ្ទាំងក្រដាសធំដែលបិទភ្ជាប់នឹងជញ្ជាំង ឬលើក្តាខៀន។ ប្រធាន គ.ក.រ ជាអ្នកកំណត់ និងបញ្ជាក់ហេតុផលថា សន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតមិនបានការ ឬបានការ ព្រមទាំងបង្ហាញឱ្យគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រួតពិនិត្យ។

ប្រធាន គ.ក.រ ឱ្យអនុប្រធាន និងលេខាធិការបូកសរុបលើ ទ.១១០៨ និងសមាជិកទី១ បូកសរុបលើផ្ទាំងក្រដាសធំ (បើសិនជាឃើញស្មើគ្នា) ប្រធាន និងលេខាធិការចុះហត្ថលេខា និងបោះត្រាលើ ទ.១១០៨ ទាំង ២ច្បាប់។ ហើយចាត់លេខាធិការ ឱ្យកត់ត្រាតួលេខចំនួនសន្លឹកបានការតាមគណបក្សនយោបាយនីមួយៗ និងសន្លឹកឆ្នោតមិនបានការទាំងអស់ចូលក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២)។ ប្រធាន គ.ក.រ ត្រូវបង្ហាញ ទ.១១០២ ចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើម្បីពិនិត្យព្រមទាំងអញ្ជើញចូលរួមចុះហត្ថលេខាជាសាក្សី។ ប្រធានត្រូវចាត់ឱ្យ សមាជិកទី២ បិទផ្សាយជាសាធារណៈនៅត្រង់ច្រកចូលទីតាំងការិយាល័យបោះ និងរាប់សន្លឹកឆ្នោត។ អ្នកសង្កេតការណ៍ត្រូវយកចិត្តទុកដាក់សង្កេតនូវព័ត៌មានដែលបានកើតឡើង ដូចមាននៅក្នុង សំណួរចាប់ពី**លេខ១៦** រហូតដល់**លេខ២៦**។

ក្នុងរយៈពេលនេះ អ្នកសង្កេតការណ៍ត្រូវសាកសួរភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ផ្សេងទៀតដើម្បីផ្ទៀងផ្ទាត់លទ្ធផល និងការយល់ឃើញចំពោះលទ្ធផលបោះឆ្នោត នៅក្នុងការិយាល័យនោះ និងការប្តឹងតវ៉ាទៅលើលទ្ធផលបោះឆ្នោត។ អ្នកសង្កេតការណ៍ត្រូវផ្តោតលើសំណួរទី២៧ និង២៨ ដោយសំណួរទាំងនេះត្រូវចម្លងទាំងស្រុងចេញពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២)។

**ចំណុចសំខាន់ដែលមិនអាចខ្វះបាន**

- អ្នកសង្កេតការណ៍ត្រូវថតលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន(ទ.១១០២)ដែលបង្ហាញដោយមន្ត្រី ឬបានបិទនៅខាងមុខការិយាល័យនោះ និងការិយាល័យផ្សេងទៀតដែលស្ថិតនៅក្នុងទីតាំងដែលខ្លួនមើល (ប្រើប្រាស់ម៉ាស៊ីនថត ឬទូរស័ព្ទដែលអាចថតរូបបាន ករណីមិនមានអ្នកសង្កេតការណ៍អាចខ្ចីមិត្តភ័ក្ត្រ សាច់ញ្ញាតិមួយថ្ងៃសិន)។
- ត្រូវកត់លទ្ធផលឆ្នោតទាំងអស់ចេញពីទម្រង់ ទ.១១០២ ចូលក្នុងទម្រង់របស់ខុមហ្វ្រែល **ខ.៧** (ត្រង់ចំណុចទី IV នៃសំណួរ ២៧ និង២៨)

- អ្នកសង្កេតការណ៍ត្រូវដើរថតឱ្យគ្រប់ការិយាល័យក្នុងទីតាំងការិយាល័យដែលខ្លួនបានសង្កេត(ពិនិត្យបន្ថែមថារូបថតមានគុណភាព មើលឃើញច្បាស់ និងប្រើការបានឬអត់)
- អ្នកសង្កេតការណ៍ម្នាក់ថត ទម្រង់ ទ.១១០២ ចំនួន ២ការិយាល័យដែលខ្លួនមើល (បើទីតាំងនោះមានការិយាល័យច្រើន)

## គន្លឹះសំខាន់ៗនៃដំណើរការរាប់សន្លឹកឆ្នោត សម្រាប់អ្នកសង្កេតការណ៍ត្រូវយកចិត្តទុកដាក់

- ការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនៅពេលបិទការិយាល័យ
- ការបង្ហាញពីភាពត្រឹមត្រូវដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដូចជា ហិបឆ្នោត ការកំណត់សន្លឹកឆ្នោតថាបានការមិនបានការ ការប្រកាសសន្លឹកឆ្នោតនៃគណបក្សនិមួយៗទទួលបាន
- ភាពត្រឹមត្រូវនៃកំណត់ហេតុផ្សេងៗ និងរបាយការណ៍ ជាពិសេសកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២)
- ជាពិសេសអ្នកសង្កេតការណ៍ត្រូវប្រើប្រាស់វិញ្ញាណរបស់ខ្លួនគឺ ស្តាប់ មើល និងភាពរហ័ស **«មានន័យថា ស្តាប់ការប្រកាសសំឡេងឆ្នោតរបស់ប្រធានជាមួយការមើលគំនូសលើសន្លឹកឆ្នោតដូចគ្នាឬអត់? និងត្រូវមើលថាអ្នកគូសសញ្ញាពិន្ទុលើក្តារខៀនឬផ្ទាំងក្រដាស់នោះត្រឹមត្រូវ ដូចការហៅរបស់ប្រធានដែរទេ?»**

### ខ.៥.១ សង្ខេបនីតិវិធីសម្រាប់សំណួរទី១៦ ដល់ទី២៨

ក្រោយពីបិទដំណើរការបោះឆ្នោត ដំណើរការរាប់សន្លឹកឆ្នោតបានចាប់ផ្តើម (មានបង្ហាញក្នុងជំពូកទី១១ ក្នុង ប.ន.យ.ស)។

**សម្រាប់សំណួរទី១៦ (ប.ន.យ.ស ជំពូកទី១០ ចំណុច១០.១.១.១ និងចំណុច១០.១.១.២)**

ប្រធានត្រូវ**មូលភ្ជិតសន្ទះបិទប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោត**ទាំងពីរនៃហិបឆ្នោត...។ ប្រធានត្រូវបិទគម្របខាងក្រៅនៃហិបឆ្នោត និងចាក់សោឃ្លុំ...។

**សម្រាប់សំណួរទី១៧ (ប.ន.យ.ស ជំពូក១០ ចំណុច ១០.២.១.៣)**

ចាត់សមាជិកទី២ និងសមាជិកទី៣ ឱ្យសហការគ្នាការពារមាត់ទ្វារ និងបង្អួចដែលបើកចំហ កុំឱ្យមានអ្នកចេញចូល...។

**សម្រាប់សំណួរទី១៨ (ប.ន.យ.ស ជំពូក១០ ចំណុច ១០.២.២)**

យោងមាត្រា ១២៣ នៃ ច.ប.យ.ស សន្លឹកឆ្នោតត្រូវរាប់នៅការិយាល័យបោះឆ្នោតនីមួយៗ ក្នុងឃុំ សង្កាត់។ ចំពោះការិយាល័យណាដែលមិនអាចរាប់សន្លឹកឆ្នោត ក្នុងការិយាល័យបោះឆ្នោតរបស់ខ្លួនបាន **ដោយករណីប្រធានស័ក្តិ ឬអសន្តិសុខ គ.ជ.ប នឹងធ្វើការណែនាំដោយឡែក**។ កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត **ត្រូវធ្វើតែមួយកន្លែងនៅការិយាល័យរាប់សន្លឹកឆ្នោតមួយដែរប្រសិនបើចាប់ផ្តើមហើយត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយពុំត្រូវឈប់សម្រាកឡើយ**។

**សម្រាប់សំណួរទី១៩ (ប.ន.យ.ស ជំពូក១០ ចំណុច ១០.២.២.២)**

ប្រតិបត្តិការរាប់សន្លឹកឆ្នោត **ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានអនុញ្ញាតឱ្យចូលមើលដំណើរការរាប់សន្លឹកឆ្នោត** នៅតាមការិយាល័យរាប់សន្លឹកឆ្នោតនិមួយៗ និងត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមាន(ទ.១១១៥) នៅមុនពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត។

**សម្រាប់សំណួរទី២០ (ប.ន.យ.ស ជំពូក១០ ចំណុច ១០.២.១.៣)**

ក្នុងនីតិវិធីមិនបានបង្ហាញឱ្យច្បាស់អំពីការបើកទ្វានោះទេ(មានចំណុច១០.២.១.៣ បានបង្ហាញខ្លះអំពីការយាមបង្អួចដែលបើកចំហដូចសំណួរ១៧) តែការិយាល័យរាប់សន្លឹកឆ្នោតគួរត្រូវបើកទ្វារ ឬបង្អួចនៅពេលដំណើរការនៃការរាប់សន្លឹកឆ្នោត ដើម្បីទុកលទ្ធភាពឲ្យអ្នកបោះឆ្នោតអាចពិនិត្យមើលពីខាងក្រៅ និងមានពន្លឺគ្រប់គ្រាន់។

**សម្រាប់សំណួរទី២១ (ប.ន.យ.ស ជំពូក១០ ចំណុច ១០.២.៦.១ និងចំណុច ១០.២.៦.៣...)**

ប្រធាន គករ **ត្រូវយកសន្លឹកឆ្នោតម្តងមួយ (១)សន្លឹកៗ** ពីពំនូកទី១ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ **ព្រមទាំងត្រូវលើកបង្ហាញសន្លឹកឆ្នោត** ដែលបានកំណត់ហើយនោះ **ដើម្បីឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បានមើលឃើញច្បាស់។ ... គាត់ត្រូវប្រកាសឱ្យឮៗនូវឈ្មោះគណបក្សនយោបាយ...។**

**សម្រាប់សំណួរទី២២ (ប.ន.យ.ស ជំពូកទី១០ ចំណុច១០.២.៦.៤)**

ផ្អែកតាមប្រកាសរបស់ប្រធាន គ.ក.រ អនុប្រធាន និងលេខាធិការ **ត្រូវគូសពិន្ទុ០១(មួយ) សម្រាប់សន្លឹកឆ្នោត០១(មួយ)សន្លឹក ដែលគណបក្សនយោបាយត្រូវទទួលបាន**...។

**សម្រាប់សំណួរទី២៣ (ប.ន.យ.ស ជំពូកទី១០ ចំណុច១០.២.៧.១)**

ទោះបីប្រធាន គ.ក.រ កំណត់ថា **ជាសន្លឹកឆ្នោតបានការក្តី ឬមិនបានការក្តី ប្រធានត្រូវប្រកាសឱ្យឮៗ អំពីហេតុផលសម្រាប់សន្លឹកឆ្នោតនោះ និងត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ធ្វើការត្រួតពិនិត្យ** សន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការនោះ និងឱ្យចោទជាសំណួរចំពោះហេតុផលនៃការកំណត់របស់ប្រធានចំពោះសន្លឹកឆ្នោតនោះ។ ក្នុងករណីនេះ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ មិនត្រូវបានអនុញ្ញាតឱ្យកាន់សន្លឹកឆ្នោតនោះឡើយ។

**សម្រាប់សំណួរទី២៤ (ប.ន.យ.ស ជំពូកទី១០ ចំណុច១០.២.៥)**

ប្រធាន គ.ក.រ ត្រូវបង្គាប់ឱ្យអនុប្រធាន និងសមាជិកទី១ឱ្យលា និងតម្រៀបសន្លឹកឆ្នោត ដែលបានចាក់ចេញពីហិបឆ្នោត ...។ បន្ទាប់មកអនុប្រធាន និងសមាជិកទី១ **ត្រូវរាប់សន្លឹកឆ្នោតទាំងពីរពំនូក រួចរាយការណ៍ជូនប្រធាន អំពីចំនួនសន្លឹកឆ្នោតសរុបដែលបានរាប់ឃើញ**។ ក្នុងករណីចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើ **មានចំនួនសរុបស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត**...។

**សម្រាប់សំណួរទី២៥ (ប.ន.យ.ស ជំពូកទី១០ ចំណុច១០.២.១៤ ចំណុច១០.៤.៣.១ និង១០.៤.៥)**

...ប្រធាន គ.ក.រ ត្រូវចាត់លេខាធិការ អនុប្រធាន និងសមាជិកទី១ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) សម្រាប់ការិយាល័យរបស់ខ្លួន តាមចំនួនដែលត្រូវប្រើប្រាស់... និង**ចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន**...។ កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត០១(មួយ)ច្បាប់ នឹងត្រូវប្រើបិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គឃ.សប។ ប្រធាន គ.ក.រ ត្រូវចាត់សមាជិកទី២ **ឱ្យបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត០១(មួយ)ច្បាប់ ជាសាធារណៈនៅត្រង់ច្រកចូលទីតាំងការិយាល័យបោះឆ្នោត** និងរាប់សន្លឹកឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការ ព្រមទាំងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន។

**សម្រាប់សំណួរទី២៦ (ប.ន.យ.ស ជំពូកទី១០ ចំណុច១០.៤.១)**

ប្រធាន គ.ក.រ ត្រូវដាក់បង្ហាញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ដូចចែងក្នុងប្រការ ១០.៤ ខាងលើ ចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើម្បីពិនិត្យ **ព្រមទាំងអញ្ជើញភ្នាក់ងារគណបក្សនយោបាយឱ្យចូលរួមចុះហត្ថលេខាជាសាក្សី**។

| ល.រ | ៦ សំណួរ | មានបញ្ហា | ចំនួនករណី | សរុប បណ្តឹង (តវ៉ាផ្ទាល់មាត់ ឬ លាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ១៦ | តើមានឃើញការ**មិនមូលភ្ជិតសន្ទះបិទប្រឡោះ**សម្រាប់ស៊កសន្លឹកឆ្នោត និង/ឬ**មិនចាក់សោឃ្លុំ**ហិបឆ្នោតដែរឬទេ? | ☐ | | | |
| ១៧ | តើមាន**ការរំខាន រារាំង ដល់ដំណើរការរាប់សន្លឹកឆ្នោត**ដែរឬទេ? | ☐ | | | |
| ១៨ | តើមានការ**ពន្យារពេលការរាប់**សន្លឹកឆ្នោត ឬបិទការិយាល័យរាប់សន្លឹកឆ្នោត កំពុងដំណើរការរាប់ដែរឬទេ? | ☐ | | | |
| ១៩ | តើមានការ**មិនអនុញ្ញាត ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ថតដំណើរការរាប់**សន្លឹកឆ្នោតដែរឬទេ? | ☐ | | | |
| ២០ | តើមាន**ការបិទទ្វារ ឬបង្អួចការិយាល័យរាប់សន្លឹកឆ្នោត**នៅពេល កំពុងដំណើរការរាប់សន្លឹកឆ្នោតដែរឬទេ? | ☐ | | | |
| ២១ | តើមានការរាប់សន្លឹកឆ្នោត ដោយ**អានញាប់ពេក** និង/ឬ **មិនបានបង្ហាញឲ្យឃើញច្បាស់ពីគំនូសសន្លឹកឆ្នោត**ដែរឬទេ? | ☐ | | | |
| ២២ | តើមានភាពមិនត្រឹមត្រូវ និង/ឬបន្លំលើការប្រកាសរាប់សន្លឹកឆ្នោតដែរឬទេ? | ☐ | | | |
| ២៣ | តើមានការ**ទទួលស្គាល់សន្លឹកឆ្នោតគូសមិនត្រឹមត្រូវ/មិនបានការ/ខូច/ឬ/និងសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងបដិសេធលើសន្លឹកឆ្នោតគូសត្រឹមត្រូវ** ដោយគ្មានការត្រួតពិនិត្យ ដែរឬទេ? | ☐ | | | |

| | | | | | |
|---|---|---|---|---|---|
| ២៤ | តើមានភាពខុសគ្នារវាងសន្លឹកឆ្នោតក្នុងហិបឆ្នោតដែលបានរាប់ឃើញ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដែរឬទេ? | ☐ | | | |
| ២៥ | តើមានករណីមិនផ្តល់ឱ្យនូវកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត( ទ.១១០២) ដល់ភ្នាក់ងារគណបក្សនយោបាយ ឬ/និងមិនបិទផ្សាយកំណត់ហេតុនេះនៅមុខការិយាល័យដែរឬទេ? | ☐ | | | |
| ២៦ | តើមានការជំទាស់និងការមិនយល់ព្រមលើការផ្ទៀងផ្ទាត់សន្លឹកឆ្នោត ការរាប់សន្លឹកឆ្នោត និងការដោះស្រាយ ឬ/និងការមិនចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែរឬទេ? | ☐ | | | |

**បើមានករណីកើតឡើង** សូមបញ្ជាក់ពីការិយាល័យ? ពេលវេលា? ជនរងគ្រោះ ជនប្រព្រឹត្ត ឬគណបក្សណា មានសកម្មភាពយ៉ាងដូចម្តេច?.....
.................................................................................................................................................................។

**សម្រាប់សំណួរទី២៧ និង២៨**

តម្រូវឱ្យអ្នកសង្កេតការណ៍ធ្វើការកត់ត្រានូវលទ្ធផលសម្លេងឆ្នោតដែលគណបក្សនយោយបាយនីមួយៗទទួលបាន ដោយស្រង់ចេញពីទម្រង់ ទ.១១០២ ឬកត់ត្រាព័ត៌មានពេលប្រធាន គ.ក.រ ប្រកាសលទ្ធផល ហើយសម្រាប់ព័ត៌មានផ្សេងទៀត សូមសាកសួរមន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត ដោយបញ្ជាក់ឱ្យច្បាស់ពីលេខការិយាល័យដែលខ្លួនបានស្រង់។

**លេខការិយាល័យបោះ/រាប់ទី១:** ☐☐☐☐

**២៧. លទ្ធផលនៃការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

| ប្រភេទសន្លឹកឆ្នោត | ចំនួនសន្លឹកឆ្នោត (ជាលេខ និងជាអក្សរ) | |
|---|---|---|
| ក) ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង | ចំនួនៈ ...............សន្លឹក | ចំនួនៈ ...........................................សន្លឹក |
| ខ) ចំនួនសន្លឹកឆ្នោតខូច | ចំនួនៈ ...............សន្លឹក | ចំនួនៈ ...........................................សន្លឹក |
| គ) ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ | ចំនួនៈ ...............សន្លឹក | ចំនួនៈ ...........................................សន្លឹក |
| ឃ) ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត | ចំនួនៈ ...............សន្លឹក | ចំនួនៈ ...........................................សន្លឹក |
| ង) ចំនួនសន្លឹកឆ្នោតដែលមានក្នុងហិបឆ្នោត {ង = ឃ = ក - (ខ + គ)} | ចំនួនៈ ...............សន្លឹក | ចំនួនៈ ...........................................សន្លឹក |

**២៨. លទ្ធផលសំឡេងឆ្នោតសម្រាប់គណបក្សនយោបាយនីមួយៗ**

| ល.រ /កូដ | ឈ្មោះគណបក្សនយោបាយ | សំលេងឆ្នោតដែលទទួលបាន (ជាលេខ និងជាអក្សរ) |
|---|---|---|
| ១ | គណបក្ស **ប្រជាជនកម្ពុជា** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |
| ២ | គណបក្ស **សង្គ្រោះជាតិ** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |
| ៣ | គណបក្ស **ហ៊្វុនស៊ិនប៉ិច** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |
| ៤ | គណបក្ស **សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |
| ៥ | គណបក្ស **ខ្មែររួបរួមជាតិ** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |
| ៦ | គណបក្ស **សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |
| ៧ | គណបក្ស **សញ្ជាតិកម្ពុជា** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |
| ៨ | គណបក្ស **អំណាចខ្មែរ** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |
| ៩ | គណបក្ស **ប្រជាធិបតេយ្យមូលដ្ឋាន** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |
| ១០ | គណបក្ស **យុវជនកម្ពុជា** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |
| ១១ | គណបក្ស **ជនជាតិដើមប្រជាធិបតេយ្យ** | ជាលេខចំនួន.......................សន្លឹក (ជាអក្សរៈ...............................................) |

| | | |
|---|---|---|
| ១២ | គណបក្ស **សាធារណរដ្ឋប្រជាធិបតេយ្យ** | ជាលេខចំនួន......................សន្លឹក (ជាអក្សរ:.............................................) |
| **សន្លឹកឆ្នោតបានការសរុប** | | ជាលេខចំនួន......................សន្លឹក (ជាអក្សរ:.............................................) |
| **សន្លឹកឆ្នោតមិនបានការសរុប** | | ជាលេខចំនួន......................សន្លឹក (ជាអក្សរ:.............................................) |
| **សន្លឹកឆ្នោតក្នុងហិបឆ្នោតសរុប** | | ជាលេខចំនួន......................សន្លឹក (ជាអក្សរ:.............................................) |

**គ. របៀបបំពេញចម្លើយចំពោះទម្រង់សំណួរក្នុងអំឡុង ថ្ងៃបោះឆ្នោត**

**មានបញ្ហា៖** នៅពេលដែលអ្នកសង្កេតការណ៍ឃើញថា **មានបញ្ហា** កើតឡើងដូចដែលបានចោទសួរ ក្នុងសំណួរណាមួយនោះ អ្នកសង្កេតការណ៍ត្រូវគូសសញ្ញា ✓**នេះ នៅក្នុងប្រអប់ទំនេរ** ☐ **ឱ្យក្លាយជារូបភាពដូចនេះ** ☑ និងត្រូវប្រាប់ពីចំនួនករណីសរុប នៃបញ្ហាមួយនោះឲ្យបានច្បាស់លាស់ តែបើក្នុងករណី**គ្មានបញ្ហា**កើតឡើងដូចដែលបានចោទសួរ ក្នុងសំណួរណាមួយនោះទេ អ្នកសង្កេតការណ៍មិនចាំបាច់គូសសញ្ញានោះទេ នោះវាបង្ហាញថា"**គ្មានបញ្ហា**"។ ក្នុងករណីអ្នកសង្កេតការណ៍បានឆ្លើយសំណួរណាមួយថា "**មានបញ្ហា**" នៃសំណួរនីមួយៗ នោះមានន័យថា វាជា**ភាពមិនប្រក្រតី** ដូចនេះចាំបាច់ត្រូវបញ្ជាក់លំអិតលើបញ្ហាមិនប្រក្រតីនីមួយៗនោះ តើមានករណីសរុបប៉ុន្មាន? បណ្តឹងដែលបានប្តឹងដោយផ្ទាល់មាត់ក្តី និងលាយលក្ខណ៍អក្សរក្តីមានចំនួនសរុបប៉ុន្មាន? និងបណ្តឹងដែលមិនទាន់បានដោះស្រាយមានសរុបប៉ុន្មាន? ហើយសូមបន្ថែមនូវរាល់ព័ត៌មានលំអិតនៅបន្ទាត់ទំនេរខាងក្រោម ដោយសរសេរលេខសំណួរដែលមានបញ្ហាកើតឡើងដូចជាទីកន្លែង ពេលវេលាកើតហេតុ ជនបង្កហេតុ ជនរងគ្រោះ និងដំណើរហេតុការណ៍នោះ។ បើសំណួរណាមួយមានបញ្ហាកើតឡើងច្រើនករណីនោះ អ្នកសង្កេតការណ៍ត្រូវបំពេញព័ត៌មានលំអិត១ករណីម្តងៗនៅក្នុងបន្ទាត់ទំនេរ ឬសរសេរក្នុងក្រដាសសៀវភៅបន្ថែម។

ករណី៖ គឺជាព្រឹត្តិការណ៍ ឬហេតុការណ៍ ឬបញ្ហាណាមួយដែលបានកើតឡើង ហើយត្រូវបានបញ្ចប់ទៅវិញ ដែលឆ្លើយតបទៅនឹងព្រឹត្តិការណ៍ ឬហេតុការណ៍ ឬបញ្ហានោះក្នុងពេលតែមួយ ឬតែមួយដង។

ដូច្នេះ បន្ទាប់ពីគូស ✓ នេះ ប្រាប់ថា មានបញ្ហា ហើយត្រូវប្រាប់ពីចំនួនករណីដែលមានដូចក្នុងឧទាហរណ៍។

<u>ឧទាហរណ៍ទី១ ៖</u>

មានជនបង្កហេតុម្នាក់បានគម្រាមកំហែងទៅអ្នកមានសិទ្ធិបោះឆ្នោតម្នាក់ឲ្យបោះឆ្នោតឲ្យខ្លួន ឬមានជនបង្កហេតុមួយក្រុមបានគម្រាមកំហែងទៅអ្នកមានសិទ្ធិបោះឆ្នោតម្នាក់ឲ្យបោះឆ្នោតឲ្យគណបក្សខ្លួនក្នុងពេលតែមួយ នោះគឺ **១ករណី** (ករណីគំរាមកំហែង)។ មួយវិញទៀត មានជនបង្កហេតុម្នាក់បានធ្វើការគម្រាមកំហែងទៅអ្នកមានសិទ្ធិបោះឆ្នោត៥នាក់ឲ្យធ្វើអ្វីមួយក្នុងពេលតែមួយ ឬតែមួយដង ឬមានជនបង្កហេតុមួយក្រុមបានធ្វើការគម្រាមកំហែងទៅអ្នកមានសិទ្ធិបោះឆ្នោត៥នាក់ ឲ្យធ្វើអ្វីមួយក្នុងពេលតែមួយ ឬតែមួយដងនោះគឺ **១ករណី** (ករណីគំរាមកំហែង)។

<u>ឧទាហរណ៍ទី២ ៖</u>

មានជនបង្កហេតុម្នាក់បានធ្វើការគម្រាមកំហែងទៅអ្នកមានសិទ្ធិបោះឆ្នោត១នាក់ឲ្យធ្វើអ្វីមួយ ហើយបានដកហូតយកឯកសារបញ្ជាក់អត្តសញ្ញាណបំរើឱ្យការបោះឆ្នោត(ឯ.អ)របស់គាត់ និងព្រមទាំងវាយដំលើអ្នកបោះឆ្នោតរូបនោះក្នុងពេលតែមួយ ឬតែមួយដងនោះ គឺមានន័យថា មាន**៣ករណី** (គំរាមកំហែង១ករណី ដកហូតឯកសារបញ្ជាក់អត្តសញ្ញាណ ១ករណី និងវាយដំលើរាងកាយ១ករណី)។

**បានប្តឹង៖** បន្ទាប់ពីបានបំពេញចំនួនករណីមួយ ឬច្រើនហើយ អ្នកសង្កេតការណ៍ត្រូវពិនិត្យបញ្ហាទាំងនោះ តើមានគេប្តឹងឲ្យដោះស្រាយដឬទេ?

**បណ្តឹងមានពីរប្រភេទគឺ៖** ទី១-បណ្តឹងផ្ទាល់មាត់ ទី២-បណ្តឹងជាលាយលក្ខណ៍អក្សរ (ការបំពេញពាក្យបណ្តឹង ទ.១២០២)

❋<u>**ការប្តឹងដោយផ្ទាល់មាត់**</u> ដែលនឹងកើតមាននៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ភាគច្រើនអ្នកប្តឹងដោយភ្នាក់ងារគណបក្ស ឬប្រជាពលរដ្ឋនៅពេលគាត់ឃើញភាពមិនប្រក្រតីណាមួយបានកើតឡើង នោះគាត់តែងតែប្តឹងតាមការនិយាយផ្ទាល់មាត់។ ក្នុងករណីធ្ងន់ធ្ងរ ហើយវាមិនត្រូវបានដោះស្រាយនោះ អ្នកសង្កេតការណ៍ត្រូវជំរុញឲ្យអ្នកនោះ ដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ដោយបំពេញ**ទម្រង់ ១២០២**។ អ្នកសង្កេតការណ៍ ត្រូវបំពេញព័ត៌មានលំអិតអំពីបណ្តឹងនោះនៅបន្ទាត់ទំនេរខាងក្រោមសំណួរនៃទម្រង់សង្កេតរបស់ខ្លួន។

**រូបខាងក្រោមជាគំរូក្នុងការគូស**

| ល.រ | សំណួរ ៦ ( គម្រាមកំហែងរារាំង និងអសន្តិសុខ) | មានបញ្ហា | ចំនួនករណី | សរុប បណ្តឹង (តវ៉ាផ្ទាល់មាត់ ឬ លាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ១ | តើមានបញ្ហាខ្វះសម្ភារៈមួយចំនួនបង្កឲ្យមានការរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ដែរឬទេ? | ☑ | 5 | 3 | 1 |
| ២ | តើមានការបដិសេធមិនឲ្យអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយចូលសង្កេតក្នុងការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោតដែរឬទេ? | ☑ | 1 | 1 | 0 |
| ៣ | តើមានការរារាំងអ្នកបោះឆ្នោតដោយវិធីផ្តល់លុយកាក់ ឬសម្ភារៈ ដើម្បីកុំឲ្យទៅបោះឆ្នោតដែរឬទេ? | ☐ | | | |
| ៤ | តើមាន**មន្ត្រីជាអាជ្ញាធរមូលដ្ឋាន ឬកងកំលាំងប្រដាប់អាវុធ** (ដែលមិនមានពាក់ប្រឡង់ដែសន្តិសុខរបស់ គ.ជ.ប) ស្លៀកពាក់ឯកសណ្ឋាន ឬមានសកម្មភាពយកអាវុធជាតិផ្ទុះ ឬប្រើពាក្យសម្តីគំរាមកំហែង បំភិតបំភ័យនៅខាងក្នុង ឬនៅបរិវេណខាងក្រៅឬក្បែរការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ដែរឬទេ? | ☑ | 10 | 2 | 1 |

**ឃ.របៀបបញ្ជូនរបាយការណ៍តាមកម្មវិធីលើទូរស័ព្ទដៃ** ( App )

អ្នកសង្កេតការណ៍ **ថ្ងៃបោះឆ្នោត** និង**រាប់សន្លឹកឆ្នោត** ត្រូវពិនិត្យការបំពេញទម្រង់ឲ្យបានគ្រប់ជ្រុងជ្រោយ ហើយរៀបចំឲ្យបានត្រឹមត្រូវ រួចធ្វើការបញ្ជូនរបាយការណ៍ដែលខ្លួនបានសង្កេត**តាមវិធីសាស្ត្រ ដូចខាងក្រោម៖**

**ឃ.១ របៀបទាញយកកម្មវិធីដាក់លើទូរស័ព្ទដៃ**

**សម្រាប់ទូរស័ព្ទប្រើកម្មវិធី Android (អែនដ្រយ ) ដូចជា Samsung, LG, Huwei,...**

១. **ជំហានទី១** ភ្ជាប់សេវាអ៊ីនធឺណិតលើទូរស័ព្ទ **ជំហានទី២** ចូលក្នុងកម្មវិធី Play Store, ត្រង់«**ស្វែងរក**» វាពាក្យ «comfrel» **ជំហានទី៣** ចុចលើរូបកម្មវិធីដែលមានអក្សរសរសេរថា«**រាយការណ៍លទ្ធផលឆ្នោត**» (**សូមមើលរូបភាពទី១**) **ជំហានទី៤** ចុចលើពាក្យថា«Install» រួចអនុវត្តតាមការណែនាំនៃកម្មវិធីតាមដំណើរការរហូតចប់ **ជំហានទី៥** ចុចបើកកម្មវិធី។

**សម្រាប់ទូរស័ព្ទ I-Phone (IOS)** អ្នកចូលទៅក្នុងកម្មវិធី App Store រួចស្វែងរកកម្មវិធីដោយវាយឈ្មោះថា «comfrel VRS» ហើយអ៊ីនស្តាល(Install) តាមការណែនាំរហូតចប់។




**រូបភាពទី១**

**រូបភាពទី២**




២. បន្ទាប់ពីចុចបើកកម្មវិធី អ្នកសង្កេតការណ៍ត្រូវបំពេញព័ត៌មានចូលក្នុងប្រអប់ដូច **រូបភាពទី២** ៖

- **ឈ្មោះអ្នកប្រើ** (បញ្ចូល**ឈ្មោះអ្នកប្រើ**ដែលខុមហ្វ្រែលបានចែកជូន ឧ. Com01)
- **ពាក្យសំងាត់** (បញ្ចូល**ពាក្យសំងាត់**ដែលខុមហ្វ្រែលបានចែកជូន ឧ. 12345)
- ក្រោយពីបំពេញ«**ឈ្មោះអ្នកប្រើ**» និង«**ពាក្យសំងាត់**»ចប់ សូមចុចលើពាក្យថា«**ពិនិត្យចូល**» (ដូចក្នុងរូបភាពទី២) ពេលនោះ កម្មវិធីនិងបើកឱ្យប្រើប្រាស់ តាមពេលវេលារាយការណ៍ ដូច **រូបភាពទី៣** បានបង្ហាញ៖
  - ○ រាយការណ៍ព័ត៌មាននៅម៉ោង៨ព្រឹក ចុចលើពាក្យ«**រាយការណ៍ភាពមិនប្រក្រតីម៉ោង៨**»
  - ○ រាយការណ៍យប់ថ្ងៃបោះឆ្នោត ឬក្រោយមួយថ្ងៃ ចុចលើពាក្យ«**រាយការណ៍ភាពមិនប្រក្រតី**»
  - ○ និងរាយការណ៍ពីលទ្ធផលឆ្នោតដែលថតចេញពី ទ.១១០២ ចុចលើពាក្យ«**រាយការណ៍លទ្ធផលបោះឆ្នោត**»




**រូបភាពទី៣**

## ឃ.២ របៀបបំពេញ និងថតទិន្នន័យចូលក្នុង App

ដើម្បីបំពេញព័ត៌មានចូលក្នុងកម្មវិធី អ្នកសង្កេតការណ៍ត្រូវមានរបាយការណ៍ក្នុងដៃ (មានន័យថា អ្នកសង្កេតការណ៍ ត្រូវបំពេញទម្រង់សំណួរលើក្រដាស់ឱ្យហើយ) ដំណាក់កាលបន្ទាប់ ចូលទៅបើកកម្មវិធី ដូចចំណុច **ឃ.១** ខាងលើ ហើយចុចលើផ្ទាំងរាយការណ៍ណាមួយ ដូច **រូបភាពទី៣** ដើម្បីរាយការណ៍ព័ត៌មាន។

<u>**ចំណាំ:**</u> **គ្រប់ការបំពេញទម្រង់រាយការណ៍លើកម្មវិធី អ្នកសង្កេតការណ៍ត្រូវកាន់ទម្រង់សង្កេតការណ៍នៅក្នុងដៃ ព្រោះវាគ្រាន់តែជាការចម្លងពីក្រដាសមកដាក់លើទូរស័ព្ទ(ផ្អែកលើក្រដាស)។**




រូបភាពទី៤




## ឃ.២.១ របៀបរាយការណ៍លើចំណុច«របាយការណ៍ម៉ោង៨» ឬ «របាយការណ៍»

ការរាយការណ៍ ផ្អែកលើកម្មវិធីដែលកំពុងតែបើកដូច **រូបភាពទី៣** អ្នកសង្កេតការណ៍ ត្រូវកាន់ទម្រង់សង្កេតការណ៍បោះរាប់(ខ.៧)នៅក្នុងដៃ រួចចុចលើពាក្យ«**រាយការណ៍ភាពមិនប្រក្រតីម៉ោង៨**» ឬ «**រាយការណ៍ភាពមិនប្រក្រតី**» (ផ្ទាំងរាយការណ៍ទាំងពីរនេះប្រើដូចគ្នា)។




រូបភាពទី៥

១. ចុចលើផ្ទាំង «**រាយការណ៍ភាពមិនប្រក្រតី**» បន្ទាប់មកចុចលើលេខការិយាល័យ (**ឱ្យមានពណ៌ក្រហម**) សូមមើល **រូបភាពទី៤** ត្រង់ «**ទីតាំងបោះឆ្នោត**»

២. សូមបញ្ចូល**ចំនួនករណី**ដែលកើតមានទៅក្នុងផ្ទាំងកម្មវិធី ដូច**រូបភាពទី៤** ម្ដងមួយសំណួរៗ (អូសពីលើចុះក្រោម) រហូតចប់សំណួរ។

៣. ក្រោយពេលបំពេញព័ត៌មានចប់ សូមចុចលើពាក្យ «**រក្សាទុក និងបញ្ជូន**» នៅផ្ទៃខាងក្រោមគេបំផុត ដូច **រូបភាពទី៥** ជាការបញ្ចប់ក្នុងការបញ្ចូលមួយដង(មួយដង មួយទម្រង់)។

## ឃ.២.២ របៀបរាយការណ៍លើចំណុច «រាយការណ៍លទ្ធផលបោះឆ្នោត»

ការរាយការណ៍លើលទ្ធផលឆ្នោត អ្នកសង្កេតការណ៍ត្រូវចាប់ផ្ដើមពីលទ្ធផលសំឡេងឆ្នោត (នៅក្នុងទម្រង់ ទ.១១០២)។

អ្នកសង្កេតការណ៍ត្រូវចាប់ផ្ដើមពីចំណុច ឃ.១ ហើយទៅបើកកម្មវិធីរហូតដល់ចំណុចរូបភាពទី២ និងទី៣ ខាងលើ។







រូបភាពទី៦

១. ចុចលើពាក្យ«**រាយការណ៍លទ្ធផលបោះឆ្នោត**» ដូចរូបភាពទី៣ រួចជ្រើសរើសការិយាល័យ (ចុចឱ្យមានពណ៌ក្រហម **ដូចរូបភាពទី៦**)

២. វាយបញ្ចូលលទ្ធផលតាមចំណុចនិមួយៗ ដូច **រូបភាពទី៦** រហូតចប់ព័ត៌មានក្នុងទម្រង់ ទ.១១០២។ ពេលបំពេញព័ត៌មានចប់ ដំណាក់កាលចុងក្រោយ ចុចលើពាក្យ «**រក្សាទុក និងបញ្ជូន**» ដូច**រូបភាពទី៥**។

**<u>ចំណាំ:</u>**

១. ការប្រើប្រាស់ផ្ទាំង«**រាយកាណ៍លទ្ធផលឆ្នោត**»នេះ ត្រូវតែមានបញ្ចូលរូបថត **ទ.១១០២** ទើបអាចបញ្ជូនចេញបាន ដូច្នេះអ្នកសង្កេតការណ៍ត្រូវតែចុចលើពាក្យ«**ទាញយករូបភាព**» នៅខាងលើកន្លែងជ្រើសរើស«**២.ឈ្មោះទីតាំង និង...**» ដូច**រូបភាពទី៧** រួចជ្រើសរើសរូបណាមួយដែលខ្លួនចង់ផ្ញើ។

២. ក្នុងករណីដែលអ្នកមានការសង្ស័យថា ឯកសារដែលអ្នកបញ្ចូលបានផ្ញើ ចេញហើយ ឬនៅ? នោះសូមអ្នកចុចលើអក្សរសរសេរពាក្យថា«**មើលទិន្នន័យមិនទាន់បញ្ជូន**» រូប**រូបភាពទី៧** នៅប៉ែកខាងលើបំផុត រួចចុចលើវា បើសិនជាមានអក្សរនៅក្នុងផ្ទាំងនេះ នោះមានន័យថា មានទិន្នន័យបញ្ជូនចេញមិនទាន់អស់ ដូច្នេះត្រូវភ្ជាប់សេវាអ៊ីនធឺណិត ហើយរកកន្លែងមានសេវា និងចុចនៅលើអក្សរដែលបានបង្ហាញនៅក្នុងផ្ទាំង«**មើលទិន្នន័យមិនទាន់បញ្ជូន**» ឱ្យអស់ទើបមានន័យថា វាបានបញ្ជូន ផ្ទុយទៅវិញ បើចុចលើវាហើយបង្ហាញផ្ទាំង«**ស**» នោះមានន័យថា ឯកសារដែលអ្នកបានបញ្ជូន បានផ្ញើចេញអស់ហើយ ។

៣. កម្មវិធីនេះ អ្នកអាចប្រើប្រាស់ជាកម្មវិធីបិទ ឬបើកបាន (Online/Offline App) មានន័យថាអ្នកបើកកម្មវិធីនៅលើទូរស័ព្ទដៃរបស់អ្នក និងបញ្ចូលព័ត៌មានឱ្យអស់ រួចអ្នកទៅរកកន្លែងមានសេវា ហើយធ្វើការបញ្ជូនចេញ ដូចបានណែនាំនៅក្នុងកន្លែង **<u>ចំណាំ</u>** ត្រង់ចំណុចទី២(**មើលទិន្នន័យមិនទាន់បញ្ជូន**) ខាងលើ។




### ឃ.៣ របៀបបញ្ជូនរបាយការណ៍ និងលទ្ធផលតាម Online

អ្នកសង្កេតការណ៍ ត្រូវបញ្ជូនរបាយការណ៍ជាពីរលើកគឺ៖

- **<u>លើកទី១.</u>** បញ្ជូនភាពមិនប្រក្រតី ឬបញ្ជាក់ថាអ្នកបានចូលដល់ការិយាល័យហើយ នៅម៉ោង៩:០០ព្រឹក (ដោយប្រើប្រាស់ផ្ទាំង **របាយការណ៍ម៉ោង៨**)
- **<u>លើកទី២.</u>** បញ្ជូនភាពមិនប្រក្រតី (ប្រើប្រាស់ផ្ទាំង **រាយការណ៍ភាពមិនប្រក្រតី**) និងលទ្ធផលឆ្នោតក្នុងផ្ទាំង «**រាយការណ៍លទ្ធផលឆ្នោត**» នៅក្រោយពេលរាប់ចប់

**<u>សេចក្តីណែនាំរួម៖</u>**

- **អ្នកសង្កេតការណ៍ និងអ្នកសង្កេតការណ៍ទទួលខុសត្រូវប្រចាំឃុំសង្កាត់**ទាំងអស់ ត្រូវផ្ញើរបាយការណ៍លទ្ធផលបោះឆ្នោត មុនគេ ក្រោយពីបញ្ចប់ការរាប់សន្លឹកឆ្នោតក្នុងការិយាល័យចប់
- អ្នកសង្កេតការណ៍ គ្រប់ទីតាំងការិយាល័យទាំងអស់ត្រូវផ្ញើរបាយការណ៍របស់ខ្លួន តាមចំណុច **ឃ.៣** ខាងលើ
- អ្នកសង្កេតការណ៍ទទួលខុសត្រូវប្រចាំឃុំសង្កាត់ទាំងអស់ ទទួលខុសត្រូវថតទម្រង់ **ទ.១១០២** នៅឃុំសង្កាត់ របស់ខ្លួនឱ្យបានគ្រប់ និងផ្ញើតាមរយៈទូរស័ព្ទដៃ នូវពេលដែលអ្នកសង្កេតការណ៍ក្នុងឃុំសង្កាត់របស់ខ្លួនមិនមានលទ្ធភាពផ្ញើមក។
- របាយការណ៍ជាក្រដាស អ្នកសង្កេតការណ៍ត្រូវប្រមូលទុកនៅអ្នកសង្កេតការណ៍ទទួលខុសត្រូវប្រចាំឃុំសង្កាត់ មានបញ្ហាកើតឡើងណាមួយ ក្រុមការងារស្នាក់ការកណ្តាល និងធ្វើការទូរស័ព្ទទៅទំនាក់ទំនងសាកសួរព័ត៌មាន។
- អ្នកសង្កេតការណ៍ណាមួយដែលមានបញ្ហាក្នុងការបញ្ចូលក្នុងកម្មវិធី ត្រូវរត់មកជួបមេក្រុម(អ្នកសង្កេតការណ៍ទទួលខុសត្រូវឃុំ សង្កាត់ ជាបន្ទាន់ដើម្បីសុំកិច្ចសហការ និងធ្វើការទំនាក់ទំនងមកស្នាក់ការកណ្តាល)
- ក្រុមការងារស្នាក់ការកណ្តាលខុមប្រែល និងធ្វើការទំនាក់ទំនងទៅអ្នកសង្កេតការណ៍ នៅមុនមួយថ្ងៃ(ថ្ងៃស) ក្នុងថ្ងៃបោះឆ្នោត(ជាពិសេសយប់បន្ទាប់ពីរាប់លទ្ធផលចប់) និងក្រោយថ្ងៃបោះឆ្នោត

**ខ.មធ្យោបាយសម្រាប់ធ្វើសេចក្តីរាយការណ៍បន្ទាន់**

លើសពីការបញ្ជូនទម្រង់សង្កេតការណ៍ដែលបានកំណត់ខាងលើ អ្នកសង្កេតការណ៍អាចធ្វើសេចក្តីរាយការណ៍បន្ទាន់នូវភាពមិនប្រក្រតីនានា និងបញ្ហាប្រឈមរបស់ខ្លួន តាមមធ្យោបាយមួយចំនួន ដូចខាងក្រោម៖

- ទូរស័ព្ទ៖ (០៧៧/០១៥/ ០៧១៦) ៣០០ ៧៦០
- អ៊ីម៉ែល៖ comfrel@online.com.kh or comfrel@comfrel.org
- Facebook: សូមរាយការណ៍ចូលទៅក្នុងក្រុម«**អ្នកសង្កេតការណ៍២០១៧**» ដោយអែត(Add)ចូលខុមហ្វ្រែលជាមុន ឬមិត្តភក្ត្រដែលមាននៅក្នុងក្រុមស្រាប់ជួយអែត(Add)។

**ច សិទ្ធិ ភារកិច្ច និងក្រមសីលធម៌របស់អ្នកសង្កេតការណ៍ .**

**ច.១ សិទ្ធិរបស់អ្នកសង្កេតការណ៍បោះឆ្នោត**

១- អាចធ្វើដំណើរសង្កេតការណ៍ក្នុងរង្វង់រាជធានី ខេត្ត ដែលខ្លួនស្នើសុំប៉ុណ្ណោះ។

២- អាចជូនដំណឹងទៅមន្ត្រីបោះឆ្នោតពាក់ព័ន្ធ និងអាជ្ញាធរដែនដីដើម្បីជួយដោះស្រាយ ក្នុងករណីអ្នកសង្កេតការណ៍មានជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ។

៣- អាចសង្កេតការណ៍នូវរាល់សកម្មភាពនានាទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលបោះឆ្នោត។

៤- អាចចេញចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៥- អាចជួប ឬនិយាយ ឬលើកសំណួរជាមួយបេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោតនៅក្រៅការិយាល័យ ។

៦- អាចថតរូប ថតវីដេអូរ នៅដំណាក់កាលពេលរាប់សន្លឹកឆ្នោត

**ច.២ ភារកិច្ចរបស់អ្នកសង្កេតការណ៍បោះឆ្នោត**

១- ត្រូវតែយល់ដឹង និង ប្រតិបត្តិគោលការណ៍ណែនាំ ពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។

២- ត្រូវមានជំហរអព្យាក្រឹត និងមិនត្រូវប្រកាន់បក្ខនយោបាយ ។

៣- ត្រូវធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធី ដោយផ្អែកតាមការណែនាំជាកំណត់របស់ អង្គការ។

៤- ត្រូវគោរពតាមការកំណត់របស់ប្រធាន ក)ៈ ក្នុងករណីមានអ្នកសង្កេតការណ៍ច្រើនលើសពី៤.ក.គ/ប.ក.ប ឬគ.ច.បួន)នាក់ សម្រាប់ការិយាល័យមួយ។

**ច.៣ បម្រាមសម្រាប់អ្នកសង្កេតការណ៍**

១- ហាមជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ ។

២- ហាមរំខាន ឬការជ្រៀតជ្រែក ឬ ស្តីបន្ទោស ក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយ ។

៣- ហាមយកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឲ្យមានគ្រោះថ្នាក់។

៤- ហាមប៉ះពាល់ឯកសារ ឬសម្ភារ បរិក្ខារបោះឆ្នោត ក្នុងនោះរួមមានសន្លឹកឆ្នោតផង។

៥- ហាមនៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ហើយមិនត្រូវថតរូប ថតវីដេអូ អ្នកបោះឆ្នោត នៅក្នុងបន្ទប់ការិយាល័យបោះឆ្នោត ។

**សូមឲ្យអ្នកសង្កេតការណ៍ទាំងអស់បំពេញការងារបានដោយជោគជ័យ និងសូមអរគុណចំពោះការលះបង់ពេលវេលាចូលរួមដ៏មានតម្លៃ និងមានសារៈប្រយោជន៍របស់អ្នកក្នុងដំណើរការសង្កេតការបោះឆ្នោតនេះ!**

# ទម្រង់សង្កេតថ្ងៃបោះឆ្នោត និងលទ្ធផលរាប់សន្លឹកឆ្នោត
# សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧

**ខ.៧**

ឈ្មោះអ្នកសង្កេតការណ៍: ..........................ភេទ: ☐ ប្រុស ☐ ស្រី ឈ្មោះទីតាំងការិយាល័យ: .....................................
លេខការិយាល័យបោះ/រាប់ទី១: ☐☐☐☐ លេខការិយាល័យបោះ/រាប់ទី២: ☐☐☐☐
ក្នុងឃុំ/សង្កាត់:....................................ក្រុង/ស្រុក/ខណ្ឌ:......................... រាជធានី/ខេត្ត:.........................................
ថ្ងៃខែឆ្នាំបំពេញទម្រង់............./ ................./២០១៧ លេខទូរស័ព្ទ:...........................................................................

✍**ចំណាំ ៖** សូមគូសសញ្ញា ✓នេះ នៅក្នុងប្រអប់ទំនេរ ☐ឱ្យដូចសញ្ញា« ☑»នេះ ដើម្បីបញ្ជាក់ថា មានបញ្ហា ឬមានភាពមិនប្រក្រតី ហើយសូមសរសេររៀបរាប់បញ្ជាក់ឲ្យបានក្បោះក្បាយនៅបន្ទាត់ទំនេរខាងក្រោមសំណួរ។

## I. និដ្ឋភាពទូទៅនៅការិយាល័យបោះ និងរាប់ឆ្នោត

| ល.រ | សំណួរ ៦ ( គម្រាមកំហែងរារាំង និងអសន្តិសុខ) | មាន បញ្ហា | ចំនួន ករណី | សរុប បណ្ដឹង (តវ៉ាផ្ទាល់មាត់ ឬ លាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ១ | តើមានបញ្ហាខ្វះសម្ភារៈមួយចំនួនបង្កឲ្យមានការរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត និង/ឬរាប់សន្លឹកឆ្នោត ដែរឬទេ? | ☐ | | | |
| ២ | តើមានការបដិសេធមិនឲ្យអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយចូលសង្កេតក្នុងការិយាល័យបោះឆ្នោត និង/ឬរាប់សន្លឹកឆ្នោតដែរឬទេ? | ☐ | | | |
| ៣ | តើមានការរារាំងអ្នកបោះឆ្នោតដោយវិធីផ្ដល់លុយកាក់ ឬសម្ភារៈ ដើម្បីកុំឲ្យទៅបោះឆ្នោតដែរឬទេ? | ☐ | | | |
| ៤ | តើមាន**មន្ត្រីជាអាជ្ញាធរមូលដ្ឋាន ឬកងកំលាំងប្រដាប់អាវុធ** (ដែលមិនមានពាក់ប្រឡង់ដែសន្តិសុខរបស់ គ.ជ.ប) ស្លៀកពាក់ឯកសណ្ឋាន និង/ឬមានសកម្មភាពយកអាវុធជាតិផ្ទុះ ឬប្រើពាក្យសម្ដីគំរាមកំហែង បំភិតបំភ័យនៅខាងក្នុង ឬនៅបរិវេណខាងក្រៅឬក្បែរការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ដែរឬទេ? | ☐ | | | |

**បើមានករណីកើតឡើង** សូមបញ្ជាក់ពីការិយាល័យ? ពេលវេលា? ជនរងគ្រោះ ជនប្រព្រឹត្ត ឬគណបក្សណា មានសកម្មភាពយ៉ាងដូចម្ដេច?.....
.........................................................................................................................................................................
.............................................................................................................................................................។

## II. ដំណើរការបោះឆ្នោត

| ល.រ | សំណួរ ៦ ( ភាពមិនប្រក្រតី នៃនីតិវិធី ) | មាន បញ្ហា | ចំនួនករណី | សរុប បណ្ដឹង (តវ៉ាផ្ទាល់មាត់ ឬ លាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ៥ | តើមានការ**មិនបង្ហាញហិបឆ្នោតទទេ** មុនពេលចាប់ផ្ដើមដំណើរការបោះឆ្នោតដែរឬទេ? | ☐ | | | |
| ៦ | តើមានការបើកការិយាល័យបោះឆ្នោត**យឺត**ជាងម៉ោង ៧:០០នាទីព្រឹក ដោយគ្មានមូលហេតុត្រឹមត្រូវដែរឬទេ? (បើកមិនតាមពេលកំណត់) | ☐ | | | |
| ៧ | តើមានភាពមិនប្រក្រតីនានាដែលនាំឱ្យ**បាត់ភាពសម្ងាត់**នៃការបោះឆ្នោតដែរឬទេ? (ដូចជាជញ្ជាំងរហែក ការសាកសួរ ការលបមើល ការ | ☐ | | | |

| | | | | | |
|---|---|---|---|---|---|
| | បើកបង្អួចមើលការថតរូប ឬការិយាល័យបោះឆ្នោតនៅក្រោយផ្ទះប្រជាពលរដ្ឋ ដែលអាចមើលឃើញ) | | | | |
| ៨ | **តើមានករណីណាមួយ ឬច្រើនខាងក្រោមបានកើតឡើងដែរឬទេ?** | | | | |
| | ៨.១ ការមិនពិនិត្យម្រាមដៃ និង/ឬមិនជ្រលក់ទឹកខ្មៅលុបលាងមិនជ្រះ | ☐ | | | |
| | ៨.២ ការមិនពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្នុងឯកសារ និងបញ្ជីបោះឆ្នោត | ☐ | | | |
| | ៨.៣ ការឲ្យសន្លឹកឆ្នោតលើសពីមួយសន្លឹក | ☐ | | | |
| ៩ | តើមានការផ្អាក ឬបិទការិយាល័យនៅពេលកំពុងដំណើរការបោះឆ្នោតជាយថាហេតុ (ហេតុដែលមិនបានដឹងជាមុនដូចជា ខ្យល់ព្យុះ រញ្ជួយផែនដី ទឹកជំនន់ អគ្គីភ័យ អសន្តិសុខ ឬបាក់អាគារ...) ដែរឬទេ? | ☐ | | | |

**បើមានករណីកើតឡើង** សូមបញ្ជាក់ពីការិយាល័យ? ពេលវេលា? ជនរងគ្រោះ ជនប្រព្រឹត្ត ឬគណបក្សណា មានសកម្មភាពយ៉ាងដូចម្តេច?.....

..............................................................................................................................................................................

...........................................................................................................................................................។

| ល.រ | សំណួរ ៦ ( សិទ្ធិអ្នកបោះឆ្នោត) | មានបញ្ហា | ចំនួនករណី | សរុប បណ្តឹង (តវ៉ាផ្ទាល់មាត់ ឬ លាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ១០ | **តើមានករណីអ្នកមានសិទ្ធិបោះឆ្នោតមិនបានបោះឆ្នោត ដោយសារមូលហេតុដូចខាងក្រោមដែរឬទេ? (ក្នុងការិយាល័យបោះឆ្នោត)** | | | | |
| | ១០.១ គ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (មានឯកសារនិងឈ្មោះក្នុងបញ្ជីបោះឆ្នោត) | ☐ | | | |
| | ១០.២ មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ | ☐ | | | |
| | ១០.៣ ខុសទិន្នន័យ (ឈ្មោះ ឬភេទ ឬថ្ងៃខែឆ្នាំកំណើត...) | ☐ | | | |
| | ១០.៤ ឈ្មោះរបស់ខ្លួនត្រូវបានបញ្ជាក់ថា បោះរួចហើយ | ☐ | | | |
| | ១០.៥ រកឈ្មោះមិនឃើញ(បាត់ឈ្មោះ)ឬរកការិយាល័យបោះឆ្នោតមិនឃើញ | ☐ | | | |
| | ១០.៦ ផ្សេងៗ.......................................................... | ☐ | | | |
| ១១ | **តើមានករណីដូចខាងក្រោមត្រូវបានអនុញ្ញាតឲ្យបោះឆ្នោតម្តងទៀតដែរឬទេ?** | | | | |
| | ១១.១ អ្នកគ្មានសិទ្ធិបោះឆ្នោត និង/ឬគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត | ☐ | | | |
| | ១១.២ អ្នកមានស្នាមទឹកខ្មៅនៅម្រាមដៃសំគាល់ថា បានបោះឆ្នោតរួចហើយ | ☐ | | | |
| ១២ | តើមានអ្នកបោះឆ្នោតបានយកសន្លឹកឆ្នោតចេញមកខាងក្រៅការិយាល័យបោះឆ្នោត ដើម្បីគូសឲ្យអ្នកបោះឆ្នោតផ្សេងទៀត ហើយយកទៅដាក់ក្នុងហិបឆ្នោតជាបន្តបន្ទាប់គ្នាដែរឬទេ? | ☐ | | | |

**បើមានករណីកើតឡើង** សូមបញ្ជាក់ពីការិយាល័យ? ពេលវេលា? ជនរងគ្រោះ ជនប្រព្រឹត្ត ឬគណបក្សណា មានសកម្មភាពយ៉ាងដូចម្តេច?.....

..............................................................................................................................................................................

...........................................................................................................................................................។

| ល.រ | សំណួរ ៦ ( ការប្តឹងតវ៉ារបស់តំណាងគណបក្សនយោបាយ) | មានបញ្ហា | ចំនួនករណី | សរុប បណ្តឹង (តវ៉ាផ្ទាល់មាត់ ឬ លាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ១៣ | តើមានការបដិសេធ ឬមិនអើពើ ឬមិនព្រមប្រគល់ទម្រង់ប្តឹងតវ៉ាឬជំទាស់(លេខ១២០២)ទៅអ្នកបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ ពីសំណាក់មន្ត្រីការិយាល័យបោះឆ្នោតដែរឬទេ? | ☐ | | | |

| | | | | | |
|---|---|---|---|---|---|
| ១៤ | តើមាន**ភាពមិនប្រក្រតីផ្សេង**ទៀតនៃនិតិវិធី ដែលពុំបានរៀបរាប់នៅសំណួរខាងលើពីទី១ ដល់ទី១៤ ដែរឬទេ? (បើមានសូមបញ្ជាក់ នៅបន្ទាត់ខាងក្រោម៖ ដូចជា ការមិនជ្រលក់ទឹកខ្មៅនៅម្រាមដៃ,...) | ☐ | | | |

**បើមានករណីកើតឡើង** សូមបញ្ជាក់ពីការិយាល័យ? ពេលវេលា? ជនរងគ្រោះ ជនប្រព្រឹត្ត ឬគណបក្សណា មានសកម្មភាពយ៉ាងដូចម្តេច?.....
..........................................................................................................................................................
.................................................................................................................................................។

១៥. សន្លឹកឆ្នោតក្រោយពេលបិទការបោះឆ្នោតក្នុងការិយាល័យនោះ(ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត និងចំនួនសន្លឹកឆ្នោត)

| **ប្រភេទសន្លឹកឆ្នោត** | **ចំនួនសន្លឹកឆ្នោត (ជាលេខ និងជាអក្សរ)** | |
|---|---|---|
| ក) ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង | ចំនួន: ...............សន្លឹក | ចំនួន: .............................................សន្លឹក |
| ខ) ចំនួនសន្លឹកឆ្នោតខូច | ចំនួន: ...............សន្លឹក | ចំនួន: .............................................សន្លឹក |
| គ) ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ | ចំនួន: ...............សន្លឹក | ចំនួន: .............................................សន្លឹក |
| ឃ) ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត **{ឃ = ក - (ខ + គ) }** | ចំនួន: ...............សន្លឹក | ចំនួន: .............................................សន្លឹក |

## III. ដំណើរការរាប់សន្លឹកឆ្នោត

| **ល.រ** | **✎ សំណួរ** | **មាន បញ្ហា** | **ចំនួនករណី** | សរុប បណ្តឹង (តវ៉ាផ្ទាល់មាត់ ឬ លាយលក្ខអក្សរ) | សរុបការជំទាស់ និងការមិនយល់ព្រមដោះស្រាយ |
|---|---|---|---|---|---|
| ១៦ | តើមានឃើញការ**មិនមួលភ្ជិតសន្ទះបិទប្រឡោះ**សម្រាប់ស៊កសន្លឹកឆ្នោត និង/ឬ**មិនចាក់សោឃ្នុំ**ហិបឆ្នោតដែរឬទេ? | ☐ | | | |
| ១៧ | តើមាន**ការរំខាន រារាំង ដល់ដំណើរការរាប់សន្លឹកឆ្នោត**ដែរឬទេ? | ☐ | | | |
| ១៨ | តើមានការ**ពន្យារពេលការរាប់**សន្លឹកឆ្នោត ឬបិទការិយាល័យរាប់សន្លឹកឆ្នោត កំពុងដំណើរការរាប់ដែរឬទេ? | ☐ | | | |
| ១៩ | តើមានការ**មិនអនុញ្ញាត ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ថតដំណើរការរាប់**សន្លឹកឆ្នោតដែរឬទេ? | ☐ | | | |
| ២០ | តើមាន**ការបិទទ្វារ ឬបង្អួចការិយាល័យរាប់សន្លឹកឆ្នោត**នៅពេល កំពុងដំណើរការរាប់សន្លឹកឆ្នោតដែរឬទេ? | ☐ | | | |
| ២១ | តើមានការរាប់សន្លឹកឆ្នោត ដោយ**អានញាប់ពេក** និង/ឬ **មិនបាន បង្ហាញឲ្យឃើញច្បាស់ពីគំនូសសន្លឹកឆ្នោត**ដែរឬទេ? | ☐ | | | |
| ២២ | តើមានភាពមិនត្រឹមត្រូវ និង/ឬបន្លំលើការប្រកាសរាប់សន្លឹកឆ្នោតដែរឬទេ? | ☐ | | | |
| ២៣ | តើមានការ**ទទួលស្គាល់សន្លឹកឆ្នោតគូសមិនត្រឹមត្រូវ/មិនបានការ/ខូច/ឬ/និងសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងបដិសេធលើសន្លឹកឆ្នោតគូសត្រឹមត្រូវ** ដោយគ្មានការត្រួតពិនិត្យ ដែរឬទេ? | ☐ | | | |
| ២៤ | តើមានភាពខុសគ្នារវាងសន្លឹកឆ្នោតក្នុងហិបឆ្នោតដែលបានរាប់ឃើញ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដែរឬទេ? | ☐ | | | |
| ២៥ | តើមានករណីមិនផ្តល់ឱ្យនូវកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត( ទ.១១០២) ដល់ភ្នាក់ងារគណបក្សនយោបាយ ឬ/និងមិនបិទផ្សាយកំណត់ហេតុនេះនៅមុខការិយាល័យដែរឬទេ? | ☐ | | | |

| | | | | | |
|---|---|---|---|---|---|
| ២៦ | តើមានការជំទាស់និងការមិនយល់ព្រមលើការផ្ទៀងផ្ទាត់សន្លឹកឆ្នោតការរាប់សន្លឹកឆ្នោត និងការដោះស្រាយ ឬ/និងការមិនចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែរឬទេ? | ☐ | | | |

**បើមានករណីកើតឡើង** សូមបញ្ជាក់ពីការិយាល័យ? ពេលវេលា? ជនរងគ្រោះ ជនប្រព្រឹត្ត ឬគណបក្សណា មានសកម្មភាពយ៉ាងដូចម្តេច?.....
........................................................................................................................................................................
...................................................................................................................................................................។

## IV. កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ចម្លងចេញពី ទ.១១០២)

**លេខការិយាល័យបោះ/រាប់ទី១:** ☐☐☐☐

**២៧. លទ្ធផលនៃការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

| ប្រភេទសន្លឹកឆ្នោត | ចំនួនសន្លឹកឆ្នោត (ជាលេខ និងជាអក្សរ) | |
|---|---|---|
| ក) ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង | ចំនួន: ...............សន្លឹក | ចំនួន: ...............................................សន្លឹក |
| ខ) ចំនួនសន្លឹកឆ្នោតខូច | ចំនួន: ...............សន្លឹក | ចំនួន: ...............................................សន្លឹក |
| គ) ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ | ចំនួន: ...............សន្លឹក | ចំនួន: ...............................................សន្លឹក |
| ឃ) ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត | ចំនួន: ...............សន្លឹក | ចំនួន: ...............................................សន្លឹក |
| ង) ចំនួនសន្លឹកឆ្នោតដែលមានក្នុងហិបឆ្នោត **{ង = ឃ = ក - (ខ + គ)}** | ចំនួន: ...............សន្លឹក | ចំនួន: ...............................................សន្លឹក |

**២៨. លទ្ធផលសំឡេងឆ្នោតសម្រាប់គណបក្សនយោបាយនីមួយៗ**

| ល.រ | ឈ្មោះគណបក្សនយោបាយ | សំលេងឆ្នោតដែលទទួលបាន (ជាលេខ និងជាអក្សរ) |
|---|---|---|
| ១ | គណបក្ស **ប្រជាជនកម្ពុជា** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ២ | គណបក្ស **សង្គ្រោះជាតិ** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ៣ | គណបក្ស **ហ៊្វុនស៊ិនប៉ិច** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ៤ | គណបក្ស **សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ៥ | គណបក្ស **ខ្មែររួបរួមជាតិ** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ៦ | គណបក្ស **សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ៧ | គណបក្ស **សញ្ជាតិកម្ពុជា** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ៨ | គណបក្ស **អំណាចខ្មែរ** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ៩ | គណបក្ស **ប្រជាធិបតេយ្យមូលដ្ឋាន** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ១០ | គណបក្ស **យុវជនកម្ពុជា** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ១១ | គណបក្ស **ជនជាតិដើមប្រជាធិបតេយ្យ** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| ១២ | គណបក្ស **សាធារណរដ្ឋប្រជាធិបតេយ្យ** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| | **សន្លឹកឆ្នោតបានការ សរុប** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| | **សន្លឹកឆ្នោតមិនបានការ សរុប** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |
| | **សន្លឹកឆ្នោតក្នុងហិបឆ្នោត សរុប** | ជាលេខចំនួន................សន្លឹក (ជាអក្សរ:..................................................) |

## IV. កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ចម្លងចេញពី ទ.១១០២)

លេខការិយាល័យបោះ/រាប់ទី២: | | | | |

### ២៧. លទ្ធផលនៃការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

| ប្រភេទសន្លឹកឆ្នោត | ចំនួនសន្លឹកឆ្នោត (ជាលេខ និងជាអក្សរ) | |
|---|---|---|
| ក) ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង | ចំនួន: ...............សន្លឹក | ចំនួន: ..........................................សន្លឹក |
| ខ) ចំនួនសន្លឹកឆ្នោតខូច | ចំនួន: ...............សន្លឹក | ចំនួន: ..........................................សន្លឹក |
| គ) ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ | ចំនួន: ...............សន្លឹក | ចំនួន: ..........................................សន្លឹក |
| ឃ) ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត | ចំនួន: ...............សន្លឹក | ចំនួន: ..........................................សន្លឹក |
| ង) ចំនួនសន្លឹកឆ្នោតដែលមានក្នុងហិបឆ្នោត {ង = ឃ = ក - (ខ + គ)} | ចំនួន: ...............សន្លឹក | ចំនួន: ..........................................សន្លឹក |

### ២៨. លទ្ធផលសំឡេងឆ្នោតសម្រាប់គណបក្សនយោបាយនីមួយៗ

| ល.រ | ឈ្មោះគណបក្សនយោបាយ | សំលេងឆ្នោតដែលទទួលបាន (ជាលេខ និងជាអក្សរ) |
|---|---|---|
| ១ | គណបក្ស **ប្រជាជនកម្ពុជា** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ២ | គណបក្ស **សង្គ្រោះជាតិ** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ៣ | គណបក្ស **ហ្វ៊ុនស៊ិនប៉ិច** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ៤ | គណបក្ស **សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ៥ | គណបក្ស **ខ្មែររួបរួមជាតិ** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ៦ | គណបក្ស **សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ៧ | គណបក្ស **សញ្ជាតិកម្ពុជា** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ៨ | គណបក្ស **អំណាចខ្មែរ** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ៩ | គណបក្ស **ប្រជាធិបតេយ្យមូលដ្ឋាន** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ១០ | គណបក្ស **យុវជនកម្ពុជា** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ១១ | គណបក្ស **ជនជាតិដើមប្រជាធិបតេយ្យ** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| ១២ | គណបក្ស **សាធារណរដ្ឋប្រជាធិបតេយ្យ** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| | **សន្លឹកឆ្នោតបានការ សរុប** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| | **សន្លឹកឆ្នោតមិនបានការ សរុប** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |
| | **សន្លឹកឆ្នោតក្នុងហិបឆ្នោត សរុប** | ជាលេខចំនួន...............សន្លឹក (ជាអក្សរ:..........................................) |